# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សកម្មភាព និងសមិទ្ធផលការងារឆ្នាំ២០២២ របស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា



## វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
## រាជធានីភ្នំពេញ ឆ្នាំ២០២២

# សកម្មភាព និងសមិទ្ធផលការងារឆ្នាំ២០២២

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ថ្ងៃ សុក្រ ៨កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក  ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២

# អារម្ភកថា

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដែលហៅកាត់ថា *វ.ស.ក.ក* បានបង្កើតនៅឆ្នាំ១៩៥៥ ដោយសមាគមអ្នកដាំកៅស៊ូនៅកម្ពុជា។ នៅឆ្នាំ ១៩៧០-១៩៩០ សកម្មភាពស្រាវជ្រាវរបស់ *វ.ស.ក.ក* ត្រូវបានផ្អាកដោយប្រទេសមានសង្គ្រាម ហើយត្រូវបានបង្កើតឡើងវិញដោយប្រកាសលេខ១០៣១.៣៧០ចត.២ខ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៩១ និងក្លាយជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយអនុក្រឹត្យលេខ៦៥អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧ និងកែសម្រួលឡើងវិញដោយអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ដោយបានប្រែក្លាយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាលជាលើកទី២ ។ នៅឆ្នាំ២០០១ *វ.ស.ក.ក* បានចូលជាសមាជិកទី១៦ របស់ របស់ IRRDB។ *វ.ស.ក.ក* ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជា អាណាព្យាបាលផ្នែកបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអាណាព្យាបាលផ្នែកហិរញ្ញវត្ថុ និងត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធយ៉ាងទូលំទូលាយដើម្បីបំពេញបេសកកម្មក្នុងនាមជាវិទ្យាស្ថានក្នុងក្របខណ្ឌនៃបទបញ្ញត្តិនៃអនុក្រឹត្យ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ព្រមទាំងគ្រប់គ្រងដោយនាយកមួយរូប និងមាននាយករងមួយចំនួនជាជំនួយការ។ *វ.ស.ក.ក* មានភារកិច្ចដឹកនាំ និងសម្រេចរាល់សកម្មភាពស្រាវជ្រាវ និងការពិសោធន៍ សំដៅជម្រុញការអភិវឌ្ឍលើគ្រប់ផ្នែក នៃដំណាំកៅស៊ូទូទៅ និងចូលរួមរាល់សកម្មភាពនៃការជម្រុញផ្នែកបច្ចេកទេសសុវឌ្ឍកម្មនៃគុណភាពកៅស៊ូ និងតម្លៃផលិតកម្ម។

*វ.ស.ក.ក* មានកិត្តិយស និងក្តីសោមនស្សរីករាយក្នុងការបង្ហាញជូននូវរបាយកាណ៍សកម្មភាពការងារស្រាវជ្រាវប្រចាំឆ្នាំ២០២២ ដើម្បីជាព័ត៌មានដល់អ្នកពាក់ព័ន្ធទៅនឹងការងារស្រាវជ្រាវ និងផលិតកម្មដំណាំកៅស៊ូ។ របាយការណ៍នេះ បង្ហាញជូននូវសកម្មភាពការងារស្រាវជ្រាវ និងសមិទ្ធផលចម្បងៗរបស់អង្គភាពចំណុះរបស់ខ្លួន រួមមាន ការបង្កាត់ពូជ ការដាំដុះនិងការពារ សរីរវិទ្យានិងអាជីវកម្ម មន្ទីរពិសោធន៍ជាតិយថាប្រភេទ ស្ថានីយអនុវត្ត ព្រមទាំងអង្គភាពពាក់ព័ន្ធមួយចំនួនទៀតរបស់ *វ.ស.ក.ក*។

លទ្ធផលការងារដែលបង្ហាញជូនក្នុងរបាយការណ៍សកម្មភាពនេះ សម្រេចបានដោយសារកិច្ចខិតខំប្រឹងប្រែងអនុវត្តការងារប្រកបដោយកិច្ចសហការយ៉ាងជិតស្និទ្ធរវាងមន្ត្រីរាជការ និយោជិក និងថ្នាក់ដឹកនាំ *វ.ស.ក.ក* ទាំងអស់នៅក្នុងការពិសោធន៍ ស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា និងការចូលរួមពីប្រតិបត្តិករកៅស៊ូពាក់ព័ន្ធទាំងអស់ ហើយនិងបណ្តាដៃគូអន្តរជាតិផ្សេងទៀតមានដូចជា៖ CIRAD, IRRDB, AFD, CATAS, HRPP, WWF ព្រមជាមួយគ្នានោះ ដោយមានការដឹកនាំដ៏ត្រឹមត្រូវរបស់ក្រុមប្រឹក្សាភិបាល និងជាពិសេសកិច្ចគាំទ្រនិងតម្រង់ទិសពីស្ថាប័នអាណាព្យាបាលរួមមាន៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ ដើម្បីជំរុញការអភិវឌ្ឍដំណាំកៅស៊ូនៅកម្ពុជាប្រកបដោយវឌ្ឍនភាព និងចីរភាព។

របាយការណ៍នេះ នឹងផ្តល់អត្ថប្រយោជន៍ដល់ប្រតិបត្តិករកៅស៊ូ និងអ្នកពាក់ព័ន្ធទាំងឡាយក្នុងវិស័យកៅស៊ូ រួមទាំងអ្នកនយោបាយ អ្នកធ្វើគោលនយោបាយ អ្នកស្រាវជ្រាវ អ្នកផ្សព្វផ្សាយ គ្រូបង្រៀន និស្សិត និងអាចទាំងកសិករទៀតផង។ សម្រាប់វិទ្យាស្ថានផ្ទាល់ របាយការណ៍នេះជាការលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ និងមន្ត្រីរបស់ខ្លួនឲ្យបន្តខិតខំស្រាវជ្រាវដើម្បីសម្រេចនូវបេសកកម្មក្នុងកិច្ចការស្រាវជ្រាវ និងផ្ទេរបច្ចេកវិទ្យានៅកម្ពុជា។

ខ្ញុំសង្ឃឹមថា របាយការណ៍នេះជាប្រភពព័ត៌មានដ៏មានសារៈសំខាន់សម្រាប់គ្រប់ស្រទាប់អ្នកប្រើប្រាស់។

ថ្ងៃ សុក្រ ៨កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២

**នាយក**

**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

**លិម ខាន់ធីវ៉ា**

# មាតិកា

ទំព័រ

អារម្ភកថា ................................................ ii
១. សេចក្តីផ្តើម ................................................ 1
២. អង្គការលេខ និងស្ថានភាពបុគ្គលិក ................................................ 2
២.១. អង្គការលេខ ................................................ 2
២.២. ស្ថានភាពបុគ្គលិក ................................................ 4
៣. ព្រឹត្តិការណ៍សំខាន់ៗ និងការគ្រប់គ្រង ................................................ 4
៤. សមិទ្ធផលរួមឆ្លើយតបទៅនឹងសូចនាករក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ ................................................ 5
៥. សមិទ្ធផលនៃការស្រាវជ្រាវ និងផ្សព្វផ្សាយក្នុងឆ្នាំ២០២២ ................................................ 6
៥.១. ចង្កោមសកម្មភាពទី១.៦.១ ការអភិរក្សនិងអភិវឌ្ឍក្លូនកៅស៊ូ និងការសិក្សាលើការអនុវត្តកសិកម្មល្អក្នុងការដាំដុះនិងថែទាំកៅស៊ូដើម្បីបង្កើនផលិតភាពកៅស៊ូ ................................................ 6
៥.១.១. ការងារស្រាវជ្រាវអំពីការបង្កាត់ពូជ ................................................ 6
៥.១.២. ការងារសរីរសាស្ត្រ និងការប្រមូលផលទឹកជ័រ ................................................ 6
៥.១.៣. ការងារដាំដុះនិងការពារ ................................................ 7
៥.២. ចង្កោមសកម្មភាពទី១.៦.២ ការសិក្សានិងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធិភាព និងការពង្រឹងគុណភាពជ័រកៅស៊ូកម្ពុជាស្របទៅតាមនិយាមអន្តរជាតិ ................................................ 7
៥.២.១. ការធ្វើតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍ក្រៅស្រុក និងក្នុងស្រុក ................................................ 7
៥.២.២. ការធ្វើតេស្តនិងពិនិត្យគុណកៅស៊ូ ................................................ 7
៥.២.៣. ការចុះបញ្ជិកា ទទួលស្គាល់ និងទទួលបានសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ................................................ 7
៥.៣. ចង្កោមសកម្មភាពទី១.៦.៣ ទទួលធ្វើសេវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យស្គាល់ជាផ្លូវការ និងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ ................................................ 8
៥.៣.១. ការពង្រឹងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស ................................................ 8
៥.៣.២. ការផ្សព្វផ្សាយបច្ចេកទេស ................................................ 8
៥.៣.៣. ការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ................................................ 9
៥.៣.៤. ការចូលរួមដៃគូស្រាវជ្រាវជាមួយភាគីអន្តរជាតិ ................................................ 9
៥.៣.៥ ការបោះពុម្ពនិងផ្សព្វផ្សាយ ................................................ 9
៥.៣.៦ គេហទំព័រវិទ្យាស្ថាន (Website) ................................................ 9
៦. សេចក្តីសន្និដ្ឋាន និងសំណូមពរ ................................................ 11
៧. ទិសដៅការងារសម្រាប់ឆ្នាំ២០២៣ ................................................ 12

## ១. សេចក្តីផ្តើម

ក្នុងបរិបទនៃការលើកស្ទួយវិស័យកសិកម្ម ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលអាណត្តិទី៦ គឺការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជាឲ្យមានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលនាំដល់ការបង្កើនប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមអភិក្រមនិងវិសាលភាពថ្មី ដើម្បីប្រែក្លាយវិស័យនេះ ពីដំណាក់កាលនៃការអភិវឌ្ឍតាមបែបវិបុលកម្ម ពោលគឺពឹងផ្អែកជាសំខាន់លើធនធានមានស្រាប់ (ធនធានដីនិងធនធានធម្មជាតិផ្សេងៗទៀត) ឈានទៅរកដំណាក់កាលថ្មីដែលផ្តោតលើប្រពលវប្បកម្ម ពោលគឺពឹងផ្អែក ជាសំខាន់លើការប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យាថ្មី កសិកម្មវៃឆ្លាត ការស្រាវជ្រាវ និងអភិវឌ្ឍយូបនីយកម្ម ព្រមទាំងការ បង្កើនសមត្ថភាពស្រោចស្រព ដើម្បីលើកកម្ពស់ផលិតភាព ពិពិធកម្មដំណាំដែលមានសក្តានុពល និងទីផ្សាររួមទាំងការ ចិញ្ចឹមសត្វ និងវារីវប្បកម្មជាលក្ខណៈពាណិជ្ជកម្ម។

ឆ្លើយតបទៅនឹងគោលដៅយុទ្ធសាស្ត្រលើកស្ទួយវិស័យកសិកម្មក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលអាណត្តិទី៦ ផែនការសកម្មភាពជាតិ ស្តីពីគំនិតផ្តួចផ្តើមសម្រាប់កាត់បន្ថយភាពអត់ឃ្លានឲ្យដល់កម្រិតសូន្យនៅកម្ពុជា ២០១៦-២០២៥ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានលើកឡើងនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្ម ២០១៩-២០២៣ ទិសដៅគោលនយោបាយរួមសំដៅ (១) បង្កើនផលិតភាព ពិពិធកម្មកសិកម្ម ការប្រកួតប្រជែង និងពាណិជ្ជូបនីយកម្មកសិកម្មនិង (២) បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានដី ព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព។ ក្នុងបរិបទនេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចដាក់ឲ្យអនុវត្តនូវកម្មវិធីចំនួន៥ និងមានចក្ខុវិស័យ «កសិកម្មកម្ពុជា ជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលនាំដល់ការកើនឡើងប្រាក់ចំណូលគ្រួសាកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា»។ ដើម្បីជំរុញកំណើនផលិតកម្មគ្រប់មុខក្នុងវិស័យកសិកម្មឲ្យបានក្នុងរង្វង់ ៥% និងបង្កើនការនាំចេញផលិតផលដំណាំកសិកម្ម ៧% ក្នុងមួយឆ្នាំ ដោយពង្រីកទំនើបកម្មកសិកម្ម បង្កើនផលិតភាពពិពិធកម្មដំណាំដែលមានសក្តានុពល និងការប្រកួតប្រជែងទីផ្សារខ្ពស់ តាមរយៈការបង្កើនការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មសំដៅបង្កើនទិន្នផលដំណាំ លើកកំពស់គុណភាពផលិតផល ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដោយផ្សារភ្ជាប់ជាមួយផលិតកម្មកសិកម្ម តាមកិច្ចសន្យា និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្មប្រកប ដោយនិរន្តរភាព។

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (វ.ស.ក.ក)ត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រគល់ភារកិច្ច ឲ្យស្ថិតនៅក្នុងកម្មវិធីទី១ គឺ៖ បង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច។ វ.ស.ក.ក ជាអង្គភាពគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតក្រោមអាណាព្យាបាលចំនួនពីរគឺ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាណាព្យាបាលផ្នែកបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាណាព្យាបាលផ្នែកហិរញ្ញវត្ថុ ព្រមជាមួយនឹងការដឹកនាំតម្រង់ទិសពីអង្គការកំពូលមួយគឺ ក្រុមប្រឹក្សាភិបាល។ ដែល វ.ស.ក.ក ត្រូវបានប្រគល់ភារកិច្ចឲ្យអនុវត្តការងារនៅក្នុងកម្មវិធីទី១ និងអនុកម្មវិធីទី៦ ស្តីអំពី៖ «លើកកម្ពស់គុណភាពការងារពិសោធន៍ និងស្រាវជ្រាវកៅស៊ូ» ដែលក្នុងនោះមានចង្កោមសកម្មភាពចំនួន៣ គឺ៖ ១.៦.១. ការអភិរក្សនិងអភិវឌ្ឍក្លូនកៅស៊ូ និងការសិក្សាលើការអនុវត្តកសិកម្មល្អក្នុងការដាំដុះ និងថែទាំកៅស៊ូដើម្បីបង្កើនផលិតភាពកៅស៊ូ ១.៦.២. ការសិក្សានិងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធិភាព និងការពង្រឹងគុណភាពជ័រកៅស៊ូកម្ពុជាស្របទៅតាមនិយាមអន្តរជាតិ ១.៦.៣. ទទួលធ្វើសេវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យស្គាល់ជាផ្លូវការ និងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ។

របាយការណ៍សកម្មភាពនេះគឺជាសមិទ្ធផលសំខាន់ៗ របស់ វ.ស.ក.ក ឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ព្រមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍកសិកម្ម ២០១៩-២០២៣ ហើយនឹងផែនការរយៈពេលខ្លី មធ្យម និងវែងរបស់ វ.ស.ក.ក ទៅតាមសូចនាករដែលបានគ្រោងទុកនៅក្នុងកម្មវិធី និងអនុកម្មវិធីដែលបានកំណត់ សំដៅរួមចំណែកក្នុងការបង្កើនផលិតភាពនិងតម្លៃបន្ថែមទៀត បង្កើនប្រភពចំណូលដល់កសិករ និងសេដ្ឋកិច្ចជាតិ នឹងការអភិវឌ្ឍដំណាំកៅស៊ូប្រកបដោយនិរន្តរភាព។

## ២. អង្គការលេខ និងស្ថានភាពបុគ្គលិក

### ២.១. អង្គការលេខ

វ.ស.ក.ក ជាអង្គភាពគ្រឹះស្ថានសាធារណៈរដ្ឋបាលតាមរយៈអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧ និងកែសម្រួលឡើងវិញដោយអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ដោយបានប្រែក្លាយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាលជាលើកទី២ ក្នុងនោះបានចង្អុលបង្ហាញអំពីភារកិច្ច ដែលមានខ្លឹមសារដូចតទៅ៖ វ.ស.ក.ក មានភារកិច្ចដឹកនាំ និងសម្រេចរាល់សកម្មភាពស្រាវជ្រាវ និងការពិសោធន៍ សំដៅជម្រុញការអភិវឌ្ឍលើគ្រប់ផ្នែកនៃដំណាំកៅស៊ូទូទៅ និងចូលរួមរាល់សកម្មភាពនៃការជម្រុញផ្នែកបច្ចេកទេស សុវឌ្ឍកម្មនៃគុណភាពកៅស៊ូ និងតម្លៃផលិតកម្ម។ ក្នុងការបង្កើនផលិតភាពកៅស៊ូ វ.ស.ក.ក បានយកចិត្តទុកដាក់ដល់ការស្រាវជ្រាវបង្កាត់ពូជកៅស៊ូ សំដៅបង្កើតនូវក្លូនកៅស៊ូកម្ពុជាដែលមានសក្តានុពល បន្សាំនឹងបម្រែបម្រួលអាកាសធាតុ មានទិន្នផលខ្ពស់ និងលូតលាស់ល្អសមស្របនឹងលក្ខណ្ឌបរិស្ថាននៃប្រទេសកម្ពុជា ការស្រាវជ្រាវសរីរវិទ្យានិងអាជីវកម្ម និងការស្រាវជ្រាវអំពីការដាំដុះនិងការពារ។ ក្នុងឆ្នាំ២០២២នេះ វ.ស.ក.ក បានអនុវត្តនិងបន្តការងារស្រាវជ្រាវ ហើយនិងតាមដានទិន្នន័យចម្ការពិសោធន៍ទាំងនៅក្នុងស្ថានីយ ទាំងនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូដែលជាសរុបមាន៦២ពិសោធន៍។ ទន្ទឹមគ្នានឹងការស្រាវជ្រាវ វ.ស.ក.ក បានរួមចំណែកយ៉ាងធំធេងនៅក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ដោយការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ ព្រមជាមួយគ្នានោះក៏បានបណ្តុះបណ្តាលនូវធនធានមនុស្ស តាមរយៈការបង្ហាត់បង្រៀននិស្សិត នៅតាមគ្រឹះស្ថានសិក្សា និងការសម្របសម្រួលឲ្យនិស្សិតធ្វើទស្សនកិច្ចសិក្សា ចម្ការពិសោធន៍ និងការដឹកនាំសារណា បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់និស្សិតមកពីគ្រឹះស្ថានបណ្តុះបណ្តាលមួយចំនួនដើម្បីបន្តវេនក្នុងការអភិវឌ្ឍដំណាំកៅស៊ូនាអនាគត។ នៅក្នុងអនុក្រឹត្យ វ.ស.ក.ក មានកាតព្វកិច្ចចំនួន ០៨ចំណុចសំខាន់ ដែលត្រូវបានរំលេចឡើងសំដៅលើការអនុវត្តឲ្យបានសម្រេចឆ្លើយតបទៅនឹងភារកិច្ចខាងលើ។

ឆ្លើយតបទៅនឹងការអនុវត្តភារកិច្ចខាងលើ អង្គការលេខមួយត្រូវបានរៀបចំឡើង ដើម្បីចង្អុលបង្ហាញអំពីកាតព្វកិច្ចរបស់បណ្តាការិយាល័យ និងបណ្តាអង្គភាពចំណុះរបស់ វ.ស.ក.ក តាមរយៈប្រកាសលេខ៩៧៦ ប្រក.កសក.ប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៣។ យោងសេចក្តីប្រកាសនេះ វ.ស.ក.ក មានការិយាល័យ និងអង្គភាពចំណុះចំនួន ០៧ រួមមាន៖

១- ការិយាល័យ រដ្ឋបាល និងបុគ្គលិក

២- ការិយាល័យ ផែនការ និងគណនេយ្យ

៣- ការិយាល័យ បង្កាត់ពូជ

៤- ការិយាល័យ ដាំដុះ និងការពារ

៥- ការិយាល័យ សរីរវិទ្យា និងអាជីវកម្ម

៦- មន្ទីរពិសោធន៍ជាតិយថាប្រភេទ មានថ្នាក់ស្មើការិយាល័យ

៧- ស្ថានីយ៍អនុវត្ត មានថ្នាក់ស្មើការិយាល័យ

# អង្គការលេខវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

## Cambodian Rubber Research Institute Organization




***យោង៖*** -អនុក្រឹត្យលេខ៦៥អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

-អនុក្រឹត្យលេខ៦៨អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមមាត្រា៥ ចំណុច៥.១ នៃអនុក្រឹត្យលេខ៦៥អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧

## ២.២ ស្ថានភាពបុគ្គលិក

មន្រ្តី វ.ស.ក.ក ក្នុងក្របខ័ណ្ឌមុខងារសាធារណៈបច្ចុប្បន្នមានចំនួនសរុប៤៨នាក់ ក្នុងនោះមានស្រ្តី ១២នាក់ និងកម្មករកិច្ចសន្យាផ្នែកចៀរជ័រ ដាំដុះ រោងចក្រ គ្រូបង្រៀន និងការងារបម្រើសេវាផ្សេងៗទៀត ដែលមានចំនួនសរុប ២៨៥នាក់។ មន្រ្តីក្នុងក្របខ័ណ្ឌមុខងារសាធារណៈទាំង៤៨នាក់ មានកម្រិតសញ្ញាបត្រដូចខាងក្រោម៖

| | |
|---|---|
| + បណ្ឌិត | ០១នាក់ |
| + បរិញ្ញាបត្រជាន់ខ្ពស់ | ០៩នាក់ |
| + បរិញ្ញាបត្រ | ៣៣នាក់ |
| + បរិញ្ញាបត្ររង | ០៣នាក់ |
| + បឋមឯកទេស | ០២នាក់ |
| និងមន្រ្តីជាប់កិច្ចសន្យា | ២០នាក់ |

# ៣. ព្រឹត្តិការណ៍សំខាន់ៗនិងការគ្រប់គ្រង

បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល វ.ស.ក.ក. ក្រោមអធិបតីភាព ឯកឧត្តម **ប៉ុល សុផា** អនុរដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃ វ.ស.ក.ក. ដើម្បីពិនិត្យវឌ្ឍនភាពការងារស្រាវជ្រាវកៅស៊ូចំនួន ០៤លើក ព្រមទាំងប្រជុំអចិន្រ្តៃយ៍ និងវិសាមញ្ញរបស់វិទ្យាស្ថានចំនួន១២លើក។

វិទ្យាស្ថានបានទទួលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ CIRAD, IRD និង GDA នៅស្ថានីយពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានជួបពិភាក្សាការងារជាមួយប្រតិភូ CIRAD អំពីកិច្ចសហប្រតិបត្តិការលើការស្រាវជ្រាវកៅស៊ូ នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

ស្ថានីយពិសោធន៍នៃវិទ្យាស្ថានបានទទួលដំណើរទស្សនកិច្ច និងការជួបសំណេះសំណាលរបស់ ឯកឧត្តម **ម៉ាន សុត្រី** រដ្ឋលេខាធិការ កសក អមដំណើរដោយ ឯកឧត្តម **ប៉ុល សុផា** អនុរដ្ឋលេខាធិការ កសក និងជាប្រធានក្រុមប្រឹក្សាភិបាល វ.ស.ក.ក. លោកអគ្គលេខាធិការរងក្រសួងកសិកម្ម និងថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូ។

វិទ្យាស្ថានបានអនុញ្ញាតឲ្យសាស្រ្តាចារ្យ និងនិស្សិតនៃមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍ នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា មកធ្វើទស្សនកិច្ចសិក្សាស្រាវជ្រាវ ស្វែងយល់អំពីដំណើរការប្រមូលទឹកជ័រ វិធីសាស្រ្តកែច្នៃកៅស៊ូសន្លឹក(RSS) និងការវិភាគគុណភាពកៅស៊ូធម្មជាតិសម្រាប់ការនាំចេញ ក្នុងគោលបំណងបង្កើននូវចំណេះដឹងដែលបានសិក្សាទ្រឹស្តីកន្លងមក។

វិទ្យាស្ថានបានទទួល និងជួបពិភាក្សាជាមួយក្រុមការងាររបស់ កសក ដែលដឹកនាំដោយលោក **អ៊ុំ សាវី** អនុប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងសហការី ដើម្បីពិភាក្សាអំពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមព័ត៌មានវិទ្យា។

វិទ្យាស្ថានបានរៀបចំបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូនៅដំណាក់កាលទី១ ដែលបានបណ្តុះបណ្តាលកសិករផលិតកៅស៊ូខ្នាតតូចចំនួន ០៤សហគមន៍ និងនៅដំណាក់កាលទី២ដល់កសិករផលិតកៅស៊ូខ្នាតតូចចំនួន ០២សហគមន៍ នៅសហគមន៍កសិកម្មទ្រទ្រង់កសិករ ឃុំអូររៃ្ស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម និងសហគមន៍កសិកម្មកសិករតំបែរ ឃុំទឹកជ្រៅ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ ហើយការបណ្តុះបណ្តាលនេះ ត្រូវបានចែកចេញជាពីរផ្នែកសំខាន់ៗ គឺផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែងនៅទីតាំងចម្ការផ្ទាល់។

វ.ស.ក.ក. និងអង្គការបណ្តាញកសិករនិងធម្មជាតិ បានរៀបចំបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗរួមមាន (១)ការរៀបចំថ្នាលពូជកៅស៊ូតាមបទដ្ឋានបច្ចេកទេស (២)អត្តសញ្ញាណកម្មក្លូនកៅស៊ូ និង(៣)ការជ្រើសរើសពូជដែលសមស្របទៅតាមទីតាំងភូមិសាស្រ្តដាំដុះ ដល់កសិករមួយក្រុមមានគ្នាសរុបចំនួន១៥នាក់ ដែលបានអញ្ជើញមកពីស្រុកចំនួន០៣៖ ស្រុកពញាក្រែក តំបែរ និងមេមត់ ខេត្តត្បូងឃ្មុំ។

វ.ស.ក.ក បានរៀបចំការបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារចំនួន១៥ក្រុមដែលមានចូលរួមសរុបចំនួន ៣៨៩នាក់ ក្នុងនោះស្រី ១៧២នាក់ ដែលអញ្ជើញមកពីសហគមន៍កសិកម្មដូចជា៖ សាមគ្គីកក់ពពេលមានជ័យ បែតងគោកស្រុក លៀងមានជ័យ កសិករតំបែរ តំបែររុងរឿង អភិរក្សពញាក្រែក កៅស៊ូគ្រួសារមេមត់ ក្តីសង្ឃឹមកសិករ ពញាក្រែករុងរឿង សេដាសែនជ័យ រំចេកមានជ័យ ហើយនឹងក្រុមផលិតកៅស៊ូសម្បូរមាស និងត្រពាំងព្រីង ស្ថិតក្នុងខេត្តត្បូងឃ្មុំ និងសហគមន៍កសិកម្មទ្រទ្រង់កសិករស្ថិតក្នុងខេត្តកំពង់ចាម។

## ៤. សមិទ្ធផលរួមឆ្លើយតបទៅនឹងសូចនាករក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣

ក្នុងរយៈពេលមួយឆ្នាំនៃការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាណាព្យាបាលផ្នែកបច្ចេកទេស និងការគាំទ្ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាណាព្យាបាលផ្នែកហិរញ្ញវត្ថុ ព្រមទាំងក្រោមការដឹកនាំតម្រង់ទិសរបស់ក្រុមប្រឹក្សាភិបាល រួមទាំងកិច្ចសហការពីថ្នាក់ដឹកនាំ និងមន្ត្រីរបស់ **វ.ស.ក.ក** ហើយជារួមសមិទ្ធផលក្នុងឆ្នាំ២០២២ វ.ស.ក.ក សម្រេចបាននូវលទ្ធផលគួរជាទីមោទនៈ ស្របទៅតាមសូចនាករ ដែលបានព្យាករណ៍ទុកដូចមានបង្ហាញក្នុងតារាង១។

**តារាង១** លទ្ធផលឆ្លើយតបទៅនឹងសូចនាករ ដែលបានព្យាករណ៍ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣

| សូចនាករលទ្ធផលក្នុងឆ្នាំ | គោលដៅប្រចាំឆ្នាំ | លទ្ធផលសម្រេចបានមកដល់បច្ចុប្បន្ន | % នៃគោលដៅសម្រេចបាន |
|---|---|---|---|
| ចង្កោមសកម្មភាពទី ១.៦.១ ការអភិរក្ស ការអភិវឌ្ឍក្លូនកៅស៊ូ ការសិក្សាលើការអនុវត្តកសិកម្មល្អលើការដាំដុះ និងថែទាំកៅស៊ូដើម្បីបង្កើនផលិតភាពកៅស៊ូ | | | |
| -ចំនួនចម្ការពិសោធន៍ដែលបានបង្កើតតាមជានស្រង់ទិន្នន័យ (ចម្ការ)<br>-ចំនួនក្លូនកៅស៊ូ ដែលអភិវឌ្ឍ អភិរក្ស និង គ្រប់គ្រង(ក្លូន)<br>-ចំនួនសំណាកទឹកជ័រត្រូវវិភាគសរីរៈសាស្ត្រ (សំណាក) | ៦២<br><br>៧៦<br><br>៥២០ | ៦២<br><br>៧៦<br><br>១២៤៧ | ១០០%<br><br>១០០%<br><br>២៤០% |
| ចង្កោមសកម្មភាពទី ១.៦.២ ការសិក្សា ការអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធភាព និងការពង្រឹកគុណភាពជ័រកៅស៊ូកម្ពុជាស្របតាមនិយាមអន្តរជាតិ | | | |
| -ចំនួនតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍ (ដង)<br>-ចំនួនតេស្តប្រៀបធៀបមន្ទីរពិសោធន៍ (ដង) ក្នុងស្រុក<br>-ការធ្វើតេស្តនិងគុណភាពកៅស៊ូ (CSR) (ដង)<br>-ការចុះបញ្ជិកា ទទួលស្គាល់ និងទទួលបានសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា | ០២<br>០ ២<br>០៤<br>០២/០២ | ០២ដង<br>០២ដង<br>០៤ដង<br>០៣រោងចក្រ/<br>០៣មន្ទីពិសោធន៍ | ១០០%<br>១០០%<br>១០០%<br>១៥០%<br>១៥០% |
| ចង្កោមសកម្មភាពទី ១.៦.៣ ទទួលធ្វើសេវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យស្គាល់ជាផ្លូវការ និងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ | | | |
| -ការដឹកនាំនិស្សិតសរសេរសារណាបញ្ចប់បរិញ្ញាបត្រ<br>-ឯកសារបច្ចេកទេស និងការពារជំងឺ<br>-ការផ្សព្វផ្សាយបច្ចេកទេសដល់ប្រតិបត្តិករកៅស៊ូ និងកសិករកៅស៊ូគ្រួសារ | ០៤<br>០៣<br>០២ | ០៤ នាក់<br>០៣ច្បាប់<br>០២ដង | ១០០%<br>១០០%<br>១០០% |

## ៥. សមិទ្ធផលនៃការស្រាវជ្រាវ និងផ្សព្វផ្សាយក្នុងឆ្នាំ២០២២

ដើម្បីអនុវត្តតាមតួនាទីនិងភារកិច្ចរបស់ខ្លួន ជាពិសេសដើម្បីចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងការសម្រេចឲ្យបាននូវគោលនយោបាយចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងឆ្នាំ២០២២ ក៏ដូចបណ្ដាឆ្នាំមុនៗកន្លងមកដែរ **វ.ស.ក.ក** បានខិតខំបន្តអនុវត្តការងារពិសោធន៍ និងស្រាវជ្រាវឆ្លើយតបទៅនឹងបរិបទនៃការអភិវឌ្ឍ ដូចមានចែងនៅក្នុងអនុក្រឹត្យស្ដីពីការបង្កើត **វ.ស.ក.ក** ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយសម្រេចបាននូវសមិទ្ធផលសំខាន់ៗ ដូចជា (១)ផ្នែកក្សេត្រសាស្ត្រ៖ ការងារដាំដុះនិងការពារ, ការងារបង្កាត់ពូជ, ការងារសរីរសាស្ត្រនិងអាជីវកម្ម។ (២)ផ្នែកមន្ទីរពិសោធន៍ជាតិយថាប្រភេទ និង(៣)ការបណ្ដុះបណ្ដាល ការផ្សព្វផ្សាយចំណេះបច្ចេកទេសនិងព័ត៌មានកៅស៊ូដល់ប្រតិបត្តិករ សមាគម និងកសិករ។ ជារួមវិទ្យាស្ថានបានធ្វើពិសោធន៍ទាំងក្នុង និងក្រៅស្ថាននីយ៍បានលទ្ធផលទៅតាមគោលបំណងនិងសូចនាករក្នុងចង្កោមកម្មវិធីសកម្មភាពទាំង០៣ តាមលំដាប់លំដោយដូចខាងក្រោម៖

### ៥.១. ចង្កោមសកម្មភាពទី១.៦.១ ការអភិរក្សនិងអភិវឌ្ឍក្លូនកៅស៊ូ និងការសិក្សាលើការអនុវត្តកសិកម្មល្អក្នុងការដាំដុះនិងថែទាំកៅស៊ូដើម្បីបង្កើនផលិតភាពកៅស៊ូ

ចង្កោមសកម្មភាពនេះមានគោលបំណងសំខាន់ក្នុងការកសាងនូវទិន្នន័យគោល និងសិក្សាពីកត្តាវិជ្ជមាននិងអវិជ្ជមានតាមការវិភាគលទ្ធផល សម្រាប់ជាអំណះអំណាងមូលដ្ឋានក្នុងការផ្សព្វផ្សាយ ផ្ដល់ជាមគ្គុទ្ទេសនិងចង្អុលបង្ហាញដល់ប្រតិបត្តិករនៅក្នុងការអភិវឌ្ឍដំណាំកៅស៊ូ ដើម្បីបញ្ចៀសនូវហានិយភ័យ ព្រមទាំងការរក្សាបាននូវនិរន្តរភាពផលិតកម្ម និងកំណើនផលចំណូលដល់អ្នកដាំកៅស៊ូ ហើយនិងការលើកស្ទួយសេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ។ ដើម្បី **វ.ស.ក.ក** សម្រេចបាននូវគោលបំណងខាងលើ សកម្មភាពចំនួន០៣ត្រូវបានដាក់ចេញ នឹងទទួលលទ្ធផលបានដូចខាងក្រោម៖

**៥.១.១. ការងារស្រាវជ្រាវអំពីការបង្កាត់ពូជ៖** បានតាមដាន និងស្រង់ទិន្នន័យចម្ការពិសោធន៍ដែលបានបង្កើតចំនួន៦២ចម្ការពិសោធន៍ ដែលបានដាំរាយប៉ាយទៅតាមទីតាំងនិងតំបន់ផ្សេងៗដូចជា (១)ស្ថានីយ៍ពិសោធន៍នៃ វ.ស.ក.ក. (២)ក្រុមហ៊ុនក្រែកខេមបូឌា(ខេត្តត្បូងឃ្មុំ) (៣)ក្រុមហ៊ុនទ្រីភាពបឹងទន្លេប្រេច(ខេត្តព្រះវិហារ) (៤)ក្រុមហ៊ុនSOCFIN-KCD (ខេត្តមណ្ឌលគីរី)។ បានថែទាំច្បារពូជកៅស៊ូទំហំ ៨,៦០ហិកតា សម្រាប់បំរើដល់ការពិសោធស្រាវជ្រាវ។ ចម្ការពិសោធន៍ដែលបើកចៀរជ័រដំបូងបានចំនួន០៣ គឺIR.AA.11, PV.AA.01, PV.AA02 និងតេស្តចៀរជ័របានចំនួន០១ចម្ការគឺ IR.GSET.02។ ការថែទាំច្បារបង្កាត់ពូជ និងអង្កេតការជ្រុះស្លឹក និងចេញផ្ការលើក្លូនកៅស៊ូចំនួន១៦ចម្ការ។ បានប្រមូលសំណាកទឹកជ័រក្នុងចម្ការពិសោធន៍ក្លូនដើម្បីវិភាគ LD សរុបបានចំនួន ១១ចម្ការ ស្មើនឹង៥៨៨សំណាក។ បានចុះអង្កេតស្ថានភាពជំងឺ Pestlotiopsis នៅខេត្តកោះកុងបានចំនួន០១លើក។

**៥.១.២. ការងារសរីរសាស្ត្រ និងការប្រមូលផលទឹកជ័រ៖** បានអភិវឌ្ឍ អភិរក្ស និងគ្រប់គ្រងក្លូនកៅស៊ូបានចំនួន៧៦ក្លូន។ បានបង្កើតចម្ការពិសោធន៍ថ្មីនិងស្រាវជ្រាវអំពីការគ្រប់គ្រងផ្ទាំងមុខចៀរលើក្លូន IRCA 317 និង RRIC100។ អនុវត្តការងារពិសោធន៍លើការលាបថ្នាំរំញោច ត្រួតពិនិត្យនិងថែទាំសម្ភារ ឧបករណ៍និងសារធាតុគីមីនៅក្នុងមន្ទីរពិសោធន៍ជីវគីមី និងសរីរវិទ្យា។ វិភាគរកស្តង់ដាសរីរសាស្ត្រទឹកជ័រ (Latex diagnosis-LD) លើប៉ារ៉ាម៉ែត្រ Inorganic Phosphorus (Pi), Sucrose (Suc) និង Thiol (RSH) ដើម្បីផ្ទៀងផ្ទាត់សារធាតុគីមី។ បានប្រមូលសំណាកនិងវិភាគសរីរទឹកជ័រ (LD) ចម្ការពិសោធន៍នានាក្នុង និងក្រៅស្ថានីយបានចំនួន៣៤ចម្ការពិសោធន៍ស្មើនឹង១២៤៧សំណាក។

**៥.១.៣. ការងារដាំដុះនិងការពារ៖** បានរៀបចំចម្ការពិសោធន៍ក្នុងផ្នែកដាំដុះនិងការពារ គឺដើម្បីធ្វើឲ្យប្រសើរឡើងនូវវិធីសាស្ត្រដាំដុះ ការអនុវត្តកសិកម្មល្អ ការគ្រប់គ្រងជីជាតិដី បង្កើនប្រសិទ្ធភាពចម្ការនិងការប្រើប្រាស់ដី បង្កើតនូវចំណូលបន្ថែមតាមរយៈការធ្វើពិពិធកម្មកៅស៊ូជាមួយនិងប្រភេទដំណាំ និងរុក្ខជាតិផ្សេងទៀត ព្រមជាមួយគ្នានោះ ក៏មានការសិក្សាអំពីទំនាក់ទំនងរវាងការលូតលាស់ និងទិន្នផល រួមជាមួយនិងកត្តាអាកាសធាតុផងដែរ។ សកម្មភាពនិងសមិទ្ធិផលសំខាន់ៗនៃការពិសោធ ដែលបានអនុវត្តនៅក្នុងផ្នែកនេះរួមមាន៖ (១)អភិវឌ្ឍន៍រុក្ខសម្ភារដាំដុះ (២)ការប្រើប្រាស់ជីលើកៅស៊ូមិនទាន់ផ្តល់ផល និងកៅស៊ូផ្តល់ផល (៣)ការធ្វើពិពិធកម្មដំណាំរួមផ្សំ និងរុក្ខជាតិព្រៃនៅចន្លោះកៅស៊ូ (៤)ដំណាំគម្របដី ផលិតកម្មជីវម៉ាស់ និងវិធានការគ្រប់គ្រងដំណាំគម្របដី (៥)ទំនាក់ទំនងរវាងការលូតលាស់និងទិន្នផល ទៅនឹងអាកាសធាតុ ហើយនិងចង្វាក់ចៀរជ័រ d3, d4 (៦)ដង់ស៊ីតេដាំដុះដើមកៅស៊ូ (៧)ឥទ្ធិពលនៃការស្រោចស្រពលើការលូតលាស់និងទិន្នផលកៅស៊ូ។

ជាលទ្ធផលចុងក្រោយនៃការអនុវត្តចង្កោមសកម្មភាព ១.៦.១ គឺ៖ ក្លូនកៅស៊ូថ្មីសមស្របនឹងលក្ខខណ្ឌអាកាសធាតុកម្ពុជាត្រូវបានវាយតម្លៃ និងដាក់បញ្ចូលក្នុង អនុសាសន៍និងផ្សព្វផ្សាយឲ្យដាំដុះ ហើយនិងរុក្ខសម្ភារកៅស៊ូត្រូវបានអភិវឌ្ឍវិធីប្រើប្រាស់ជីមានប្រសិទ្ធភាពធានាដល់ការលូតលាស់កូនកៅស៊ូ និងកំណើនទិន្នផលនិងការថែទាំកៅស៊ូត្រូវបានណែនាំ។

### ៥.២. ចង្កោមសកម្មភាពទី១.៦.២ ការសិក្សានិងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធភាព និងការពង្រឹងគុណភាពជ័រកៅស៊ូកម្ពុជាស្របទៅតាមនិយាមអន្តរជាតិ

គោលបំណងសំខាន់នៃចង្កោមសកម្មភាព១.៦.២គឺ សំដៅធ្វើឲ្យប្រសើរឡើងនូវខ្សែច្រវ៉ាក់តម្លៃកៅស៊ូកម្ពុជា និងកិត្យានុភាពផលិតផលយថាប្រភេទកៅស៊ូកម្ពុជាលើទីផ្សារអន្តរជាតិ ដើម្បីទទួលបាននូវតម្លៃសមស្រប បង្កើនចំណូលដល់អ្នកដាំដុះកៅស៊ូ និងជំរុញនូវកំណើនសេដ្ឋកិច្ចសង្គមជាតិ។ ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួន០៣ត្រូវបានដាក់ចេញដូចខាងក្រោម៖

**៥.២.១. ការធ្វើតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍ក្រៅស្រុក និងក្នុងស្រុក៖** បានធ្វើតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍ក្រៅស្រុក (Round Robin Crosscheck) បានចំនួន០២លើក គឺការធ្វើតេស្តលើកទី១២៦ និងការធ្វើតេស្តលើកទី១២៧ ជាមួយសមាគមកៅស៊ូអន្តរជាតិ International Rubber Association (IRA)។ បានធ្វើតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍ក្នុងស្រុកចំនួន០២លើក ដែលមានចំនួន០៩មន្ទីរពិសោធន៍មូលដ្ឋាន បានចូលរួមធ្វើតេស្ត ដើម្បីពង្រឹងគុណភាព និងការគ្រប់គ្រងមន្ទីរពិសោធន៍មូលដ្ឋាន។

**៥.២.២. ការធ្វើតេស្តនិងពិនិត្យគុណកៅស៊ូ៖** បានធ្វើតេស្តនិងពិនិត្យគុណកៅស៊ូដុំ(TSR) ចំនួន១០សំណាក ព្រមទាំងបានធ្វើតេស្តកៅស៊ូសន្លឹក(RSS) របស់ វ.ស.ក.ក. សរុបចំនួន៧២សំណាក។ បានធ្វើព្យាសកម្មកូនទំងន់ នៅនាយកដ្ឋានមន្ទីរពិសោធមាត្រាសាស្ត្រជាតិ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍។

**៥.២.៣. ការចុះបញ្ជិកា ទទួលស្គាល់ និងទទួលបានសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា៖** គឺជាការចុះពិនិត្យបណ្តារោងចក្រកែច្នៃយថាប្រភេទកម្ពុជា(CSR) និងយកសំណាកមកធ្វើតេស្តពិនិត្យគុណភាព សំដៅធ្វើការតម្រង់ទិស និងកែលម្អនូវចំណុចខ្វះខាត ដើម្បីលើកកម្ពស់គុណភាពផលិតផលកៅស៊ូកម្ពុជា។ បានចុះបញ្ជិកាទទួលស្គាល់ និងទទួលបានសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ជូនរោងចក្របានចំនួន០៣រោងចក្រ និងមន្ទីរពិសោធន៍ចំនួន០៣មន្ទីរពិសោធន៍មូលដ្ឋាន។ បានទទួលធ្វើសវនកម្មផ្ទៃក្នុង និងក្រៅពីការិយាល័យទទួលស្គាល់អន្តរជាតិ។ ជាលទ្ធផលរោងចក្រកែច្នៃកៅស៊ូ យថាប្រភេទកៅស៊ូកម្ពុជា(CSR)ចំនួន១៦រោងចក្រ និងមន្ទីរពិសោធន៍ចំនួន០៩មន្ទីរពិសោធន៍មូលដ្ឋាន ត្រូវបានទទួលស្គាល់ និងទទួលបានសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជាពី វ.ស.ក.ក។

ជាលទ្ធផលចុងក្រោយនៃការអនុវត្តចង្កោមសកម្មភាព១.៦.២ គឺការប្រមូលផលកៅស៊ូប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច និងនិរន្តរភាពចម្ការកៅស៊ូ និងបង្កើនបាននូវប្រសិទ្ធភាពពលកម្ម ហើយនិងវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូត្រូវទទួលស្គាល់ជាអន្តរជាតិ តាមរយៈ IRA ទទួលសិទ្ធចេញវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ។

### ៥.៣. ចង្កោមសកម្មភាពទី១.៦.៣ ទទួលធ្វើសវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យស្គាល់ជាផ្លូវការនិងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ

ចង្កោមសកមក្មភាពទី១.៦.៣ មានក្នុងគោលបំណងក្នុងការកសាងធនធានមនុស្សប្រកបដោយប្រសិទ្ធភាពទាំងបរិមាណនិងគុណភាព រួមផ្សំនឹងការបង្កើមសមត្ថភាពនិងទេពកោសល្យរបស់អ្នកគ្រប់គ្រង អ្នកស្រាវជ្រាវ និងសេវាទ្រទ្រង់ ដើម្បីជុំរុញការងារពិសោធន៍និងស្រាវជ្រាវឲ្យទទួលបាននូវលទ្ធផលល្អ ការកសាងនូវទិន្នន័យគ្រឹះឲ្យបានរឹងមាំ ព្រមជាមួយគ្នានោះក៏មានការកែលម្អនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើម្បីផ្តល់នូវភាពកក់ក្តៅក្នុងការរស់នៅនិងបរិស្ថានបំពេញការងារដល់ មន្ត្រីនិងនិយោជិក ដែលជាចលករសំខាន់ចូលរួមនៅក្នុងការជុំរុញដល់ការងារស្រាវជ្រាវនិងអភិវឌ្ឍប្រកបដោយជោគជ័យ និងចីរភាព។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ចេញដូចខាងក្រោម៖

**៥.៣.១. ការពង្រឹងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស៖** មន្ត្រីនឹងថ្នាក់ដឹកនាំនៃ វ.ស.ក.ក បានចូលរួមបង្រៀននៅសាលាជាតិកសិកម្មកំពង់ចាម ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្ម ជំនាញវិទ្យាសាស្ត្រដំណាំកៅស៊ូ លើមុខវិជ្ជាការវិភាគសរីរសាស្ត្រទឹកជ័រ។ ការដឹកនាំនិស្សិតស្រាវជ្រាវ និងសរសេរសារណាបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានចំនួន០៤នាក់មកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលមានប្រធានបទ (១)ប្រៀបធៀបការលូតលាស់និងទិន្នផលក្លូនកៅស៊ូចំនួន០៨ក្នុងចម្ការពិសោធន៍IR.AA.07 នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (២)អត្រារស់នៃការបំបៅរបស់ក្លូនកៅស៊ូ (៣)ប្រសិទ្ធភាពនៃការប្រើប្រាស់ជីលើកៅស៊ូផ្តល់ផលក្លូនRRIM 712 និង(៤)ឥទ្ធិពលនៃចង្វាក់និងកំហាប់នៃការលាបថ្នាំរំញោចលើសក្តានុពលទិន្នផលក្លូន PB 217 នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។ ថ្នាក់ដឹកនាំវិទ្យាស្ថាន និងមន្ត្រីនិយោជិតក្រោមឱវាទវិទ្យាស្ថាន បានចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំផ្សេងៗទាំងដោយផ្ទាល់ និងតាមប្រព័ន្ធ Zoom នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថាប័ន/អង្គភាពនានា ចំនួន៦៤លើក មានអ្នកចូលរួមចំនួន២៤នាក់ នារី០៤នាក់ ឬ១៦.៦%។ បានចូលរួមវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗនៅក្រៅប្រទេសចំនួន០២លើក មានអ្នកចូលរួម០២នាក់។ ថ្នាក់ដឹកនាំ និងមន្ត្រីវិទ្យាស្ថានបានកំពង់សហការជាមួយនិស្សិតថ្នាក់បណ្ឌិតមកពីសាកលវិទ្យាល័យ Kasetsart ក្នុងការស្រាវជ្រាវអំពីការទាញយកអាស៊ីត furan fatty ពីទឹកជ័រ។

**៥.៣.២. ការផ្សព្វផ្សាយបច្ចេកទេស៖** ការបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារចំនួន១៥ក្រុម ដែលអញ្ជើញមកពីសហគមន៍កសិកម្មដូចជា៖ សាមគ្គីកក់ ពពេលមានជ័យ បៃតងគោកស្រុក លៀងមានជ័យ កសិករតំបែរ តំបែររុងរឿង អភិរក្សពញាក្រែក កៅស៊ូគ្រួសារមេមត់ ក្តីសង្ឃឹមកសិករ ពញាក្រែករុងរឿង សេដាសែនជ័យ រំចេកមានជ័យ ហើយនិងក្រុមផលិតកៅស៊ូសម្បូរមាស និងត្រពាំងព្រីង ស្ថិតក្នុងខេត្តត្បូងឃ្មុំ និងសហគមន៍កសិកម្មទ្រទ្រង់កសិករស្ថិតក្នុងខេត្តកំពង់ចាម ដែលមានអ្នកចូលរួមសរុបចំនួន៣៨៩នាក់ ក្នុងនោះនារីចំនួន១៧២នាក់ ឬ ៤៤.២១%។ ការទទួលកសិករកៅស៊ូគ្រួសារមកពីខេត្តត្បូងឃ្មុំ ចុះសិក្សាស្វែងយល់ពីច្បារពូជកៅស៊ូនៅស្ថានីយពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាបានចំនួន១លើក សរុបចំនួន១៥នាក់ ក្នុងនោះនារីមានចំនួន០២នាក់ ឬ១៣.៣%។ ការបង្ហាញដល់កសិករកៅស៊ូគ្រួសារ នៅចម្ការអំពីការអនុវត្តកសិកម្មល្អលើការប្រមូលផលទឹកជ័រ និងបណ្តុះបណ្តាលបច្ចេកទេសប្រមូលផលទឹកជ័រ នៅស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ដែលមានអ្នកចូលរួមសរុបចំនួន ៧៦នាក់ក្នុងនោះនារីចំនួន៣២នាក់ ឬ ៤២.១០%។ ការទទួលនិស្សិតមកពីប្រទេសជប៉ុនចំនួន០៩នាក់ និងនិស្សិតខ្មែរចំនួន០៣នាក់ ដើម្បីស្វែងយល់អំពីដំណើរការនៃចង្វាក់ផលិតកម្មនៃដំណាំកៅស៊ូ នៅប្រទេសកម្ពុជា។

**៥.៣.៣. ការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត៖** ការសាងសង់អាគារទីស្នាក់ការវិទ្យាស្ថាននៅភ្នំពេញ, ការជួសជុលផ្ទះស្នាក់នៅចំនួន១០ខ្នង បណ្តាញទឹក និងបណ្តាញភ្លើងរបស់កម្មករក្នុងភូមិ៣២, ការជួសជុលសាលារៀន សាលាសន្និសីទ/សន្សំកុសលនៅក្នុងភូមិ៣២, ការជួសជុលលាបថ្នាំអាគារការិយាល័យ និងអាគារស្នាក់នៅរបស់មន្ត្រីរាជការនៅក្នុងស្ថានីយ, ការជួសជុលផ្លូវក្នុងចម្ការកៅស៊ូពិសោធន៍របស់ **វ.ស.ក.ក.** និងការរៀបចំសោភ័ណ្ឌភាពនៅមុខអគារការិយាល័យ និងនៅមុខមន្ទីរពិសោធន៍ជាតិយថាប្រភេទក្នុងស្ថានីយ៍។

**៥.៣.៤. ការចូលរួមដៃគូស្រាវជ្រាវជាមួយភាគីអន្តរជាតិ៖** ក្នុងទិសដៅពង្រឹងការងារស្រាវជ្រាវ និងផ្ទេរបច្ចេកវិទ្យាកៅស៊ូដល់ប្រតិបត្តិករឲ្យកាន់តែមានប្រសិទ្ធភាព ហើយនិងការទាញយកអត្ថប្រយោជន៍បច្ចេកវិទ្យាកៅស៊ូ ពីបណ្តាប្រទេសអភិវឌ្ឍនានា **វ.ស.ក.ក** បានធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាវិទ្យាស្ថាននិងអង្គការអន្តរជាតិជាច្រើនរួមមាន៖

❖ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB)

ជាបណ្តាញស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូ ដែលប្រមូលផ្តុំរាល់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូធម្មជាតិស្ទើរតែគ្រប់ប្រទេសផលិតកៅស៊ូធម្មជាតិទាំងអស់ដែលមាន៩៥% នៃបរិមាណផលិតផលកៅស៊ូធម្មជាតិនៃពិភពលោក។ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ជាមួយបណ្តាប្រទេសជាសមាជិក IRRDB និងការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូកម្ពុជា។ នៅឆ្នាំ២០១៦ ប្រទេសកម្ពុជា បានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសន្និសីទ និងកិច្ចប្រជុំប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិស្តីអំពី "***និរន្តរភាពនៃឧស្សាហកម្មកៅស៊ូធម្មជាតិ បញ្ហា ការប្រឈម និងកាលានុវត្តភាព***" ដែលបានប្រព្រឹត្តិទៅចាប់ពីថ្ងៃទី២១-២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅខេត្តសៀមរាប ដោយមាន គណៈប្រតិភូពីបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិចំនួន១៦ និងប្រទេសជាដៃគូចំនួន០២ផ្សេងទៀត ព្រមជាមួយនិងភ្ញៀវចូលរួមសរុប ចំនួន៣៣០នាក់។ នៅឆ្នាំ២០១៧ **វ.ស.ក.ក** បានសហការជាមួយ IRRDB ក្នុងការរៀបចំសិក្ខាសាលាអន្តរជាតិ IRRDB-Workshop ស្តីអំពី ***"ការផ្ទេរបច្ចេកវិទ្យាដល់ផលិតករកៅស៊ូ និងកៅស៊ូគ្រួសារ"*** ដែលបានប្រព្រឹត្តិទៅចាប់ពីថ្ងៃ ទី១២-១៣ ខែកក្កដា ឆ្នាំ២០១៧ នៅសណ្ឋាគារ សាន់វ៉េ រាជធានីភ្នំពេញ ដោយមានភ្ញៀវពីបណ្តាសមាជិក IRRDB ចំនួន០៩ ប្រទេសគឺ៖ *កម្ពុជា ចិន ថៃ បារាំង ម៉ាឡេស៊ី ស្រីលង្កា ហ្វីលីពីន វៀតណាម និងអូស្ត្រាលី* អញ្ជើញចូលរួមសរុបចំនួន១៦៩នាក់។

នៅឆ្នាំ២០២២នេះ វ.ស.ក.ក បានចូលរួមប្រជុំតាមប្រព័ន្ធអនឡាញប្រចាំឆ្នាំចំនួន០៤លើកជាមួយក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB) និងការចូលរួមប្រជុំជាមួយក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB) ដោយផ្ទាល់ចំនួន០២លើក។

❖ កិច្ចសហប្រតិបត្តិការជាមួយ CIRAD

ក្នុងការពង្រឹងសមត្ថភាពនិងបង្កើននូវប្រសិទ្ធិភាពសិក្សាស្រាវជ្រាវអំពី បច្ចេកទេសនិងវិទ្យាសាស្ត្រដំណាំកៅស៊ូ **វ.ស.ក.ក** បានធ្វើសហប្រតិបត្តិការជាមួយ *មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិស្រាវជ្រាវកសិកម្ម សម្រាប់ការអភិវឌ្ឍន៍ (CIRAD)* នៃប្រទេសបារាំង លើការងារស្រាវជ្រាវផ្នែក កសិរុក្ខសាស្ត្រ បង្កាត់ពូជ ការប្រមូលផលជ័រនិងសរីរសាស្ត្រទឹកជ័រ ជាមួយជំនាញការនៃមជ្ឈមណ្ឌលសហប្រតិបត្តិការស្រាវជ្រាវអន្តរជាតិ ដើម្បីអភិវឌ្ឍកសិកម្ម (CIRAD)។ ជំនាញការCIRAD ម្នាក់បានមកប្រចាំការនៅវិទ្យាស្ថាន។

❖ កិច្ចសហប្រតិបត្តិការជាមួយ CATAS

កិច្ចសហប្រតិបត្តិការរវាង **វ.ស.ក.ក** និងបណ្ឌិតសភា វិទ្យាសាស្ត្រកសិកម្មត្រូពិកចិន (Chinese Academy of Tropical Agricultural Sciences-CATAS) ត្រូវបានរៀបចំឡើងលើការងារស្រាវជ្រាវកៅស៊ូរួមគ្នាជាមួយបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន (CATAS)។ ក្រុមការងារ CATAS បានផ្តល់កូនកៅស៊ូជាលិកា (Tissue Culture Plant) ចំនួន២៥០០កូនដល់វិទ្យាស្ថាន ។

❖ កិច្ចសហប្រតិបត្តិការជាមួយ WWF

ការសហប្រតិបត្តិការរវាង វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាមួយអង្គការ WWF។ នៅឆ្នាំ២០២២នេះ វ.ស.ក.ក បានសហការក្នុងការរៀបចំចម្ការបង្ហាញអំពីការអនុវត្តកសិកម្មល្អលើការប្រមូលផលទឹកជ័រ និងចម្ការបង្ហាញអំពីការកែលម្អបច្ចេកទេសលើការប្រមូលផលទឹកជ័ររបស់កៅស៊ូគ្រួសារនៅខេត្តមណ្ឌលគិរី (ចំនួន១០ចម្ការ) និងសហការក្នុងបណ្តុះបណ្តាលបច្ចេកទេសកៅស៊ូដល់កសិករកៅស៊ូគ្រួសារ។

**៥.៣.៥ ការបោះពុម្ពនិងផ្សព្វផ្សាយ៖** វិទ្យាស្ថានបានបោះពុម្ពរបាយការណ៍និងសមិទ្ធផលប្រចាំឆ្នាំ២០២១ សៀវភៅផែនការយុទ្ធសាស្ត្រស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាកៅស៊ូឆ្នាំ២០២៣-២០៣០ នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឯកសារបច្ចេកទេសកៅស៊ូ និងឯកសារការណែនាំអំពីជំងឺកៅស៊ូផ្សេងៗទៀតសរុបទាំងអស់មានចំនួន ១៣ ប្រភេទ ស្មើនឹង១៣០០០ច្បាប់ ។

**៥.៣.៦ គេហទំព័រវិទ្យាស្ថាន(Website)៖** ក្នុងរយៈពេលមួយឆ្នាំ២០២២ នេះមានអ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកៅស៊ូតាមរយៈគេហទំព័រ https://crri.com.kh របស់វិទ្យាស្ថានសរុបចំនួន ៧៩ ៦៨០នាក់។

ដើម្បីធានាដល់ភាពជោគជ័យ លើសកម្មភាពនៃការអនុវត្តគម្រោងដោយផ្ទៀងផ្ទាត់លទ្ធផលដែលសម្រេចបានជាមួយនឹងសូចនាករ ដែលបានកំណត់នៅក្នុងផែនការ ការពិនិត្យ តាមដាន និងវាយតម្លៃគឺនឹងត្រូវធ្វើឡើង។ ការវាយតម្លៃនៃការអនុវត្តនេះត្រូវបានធ្វើឡើងនៅពេលកំពុងអនុវត្តរហូតដល់ការបញ្ចប់នៃគម្រោង ដោយនាយកដ្ឋានផែនការនិងស្ថិតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈរបាយការណ៍ប្រចាំខែ របាយការណ៍ត្រីមាស របាយការណ៍ឆមាស របាយការណ៍ប្រចាំឆ្នាំ និងការចុះវាយតម្លៃដោយផ្ទាល់រៀងរាល់ឆ្នាំ។ វ.ស.ក.ក ក៏មានការរៀបចំជាគណៈកម្មការវាយតម្លៃផ្ទៃក្នុងផ្ទាល់ខ្លួនផងដែរ សម្រាប់តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងធានាបាននូវភាពច្បាស់លាស់ ហើយនិងភាពជោគជ័យនៃការអនុវត្តគម្រោង។

## ៦.សេចក្តីសន្និដ្ឋាន និងសំណូមពរ

ការងារអនុវត្តសម្រេចបាន១០០% ធៀបទៅនឹងចំណុចដៅដែលបានកំណត់នៅក្នុងផែនការថវិកាតាមកម្មវិធី មិនតែប៉ុណ្ណោះសកម្មភាពស្រាវជ្រាវជាច្រើនទៀត ត្រូវបានអនុវត្តក្រៅពីផែនការដែលបានកំណត់នៅក្នុងកម្មវិធី។ លទ្ធផលការងារ ដែលវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាសម្រេចបាននេះ ដោយសារមានផែនការការងារច្បាស់លាស់ និងកិច្ចសហការយ៉ាងជិតស្និទ្ធ រវាងមន្ត្រីរាជការ និយោជិតទាំងអស់ ជាមួយថ្នាក់ដឹកនាំ **វ.ស.ក.ក** ក្នុងការអនុវត្តតួនាទីភារកិច្ច និងមានការទទួលខុសត្រូវ ក្នុងបេសកកម្មរបស់ខ្លួននិងផែនការ ដែលបានកំណត់ ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់ក្រុមប្រឹក្សាភិបាល ព្រមជាមួយគ្នានោះ ក៏មានការយកចិត្តទុកដាក់ ចង្អុលបង្ហាញ និងការគាំទ្រពីស្ថាប័នជំនាញជាអណាព្យាបាលរួមមាន៖ *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ* ក្នុងការជុំរុញ ការអភិវឌ្ឍវិស័យកៅស៊ូនៅកម្ពុជា ស្របតាមគោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០១៩-២០២៣។ សកម្មភាព និងលទ្ធផលការងារខាងលើនេះ សម្រេចបានដោយមានការចូលរួមពីបណ្តាដៃគូជាតិរួមមានប្រតិបត្តិករកៅស៊ូទាំងអស់ដែលបានផ្តល់ការទុកចិត្ត ចូលរួមនិងគាំទ្រ ជាងនេះទៅទៀតគឺការចូលរួមសហការពីបណ្តាដៃគូអន្តរជាតិពាក់ព័ន្ធដូចជា៖ CIRAD, AFD, IRRDB, HRPP, CATAS, WWF,...។

ក្នុងបរិបទទីផ្សារសេរី ការលើកស្ទួយភាពប្រកួតប្រជែង និងសមាហរណកម្មក្នុងតំបន់ ហើយក៏ដូចទៅនឹងកង្វះខាត កម្លាំងពលកម្មក្នុងវិស័យកសិកម្មផងដែរនោះ និងថ្វីត្បិតតែកន្លងមក វិទ្យាស្ថានសម្រេចបាននូវលទ្ធផលយ៉ាងគាប់ប្រសើរ ប៉ុន្តែវិទ្យាស្ថានបាននិងកំពុងតែជួបប្រទះនូវ (១)កង្វះមន្ត្រីជំនាញតាមផ្នែកនីមួយៗ ដែលទន្ទឹមនឹងគ្នានោះ មន្ត្រីជំនាញមួយចំនួនកាន់តែចាស់ (២)មធ្យោបាយសម្រាប់បំពេញបេសកម្ម ការចុះធ្វើពិសោធន៍ និងតាមដាននៅតាមខេត្តមានសភាពកាន់តែទ្រុឌទ្រោម និងមិនគ្រប់គ្រាន់ឆ្លើយតបទៅនឹងវឌ្ឍនភាពនៃការពិសោធន៍ (៣)កង្វះមន្ទីពិសោធនិងសំភារៈដែលជួយគាំទ្រលើដំណើរការពិសោធន៍ស្រាវជ្រាវ (៤)មិនមានការលើកទឹកចិត្តណាមួយដល់អ្នកវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវ និងអ្នកបម្រើការងារគាំទ្ររបស់វិទ្យាស្ថាន (៥)កង្វះកំលាំងពលកម្មក្នុងការថែទាំ និងចៀរជ័រកៅស៊ូ។ ដូច្នេះដើម្បីលើកស្ទួយវិស័យស្រាវជ្រាវដែលរាជរដ្ឋាភិបាលចាត់ទុកជាឆ្អឹងខ្នងនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ វិទ្យាស្ថានសំណូមពរដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាអាណាព្យាបាល មេត្តាពិនិត្យលទ្ធភាពដោះស្រាយ ឬកាត់បន្ថយ នូវបញ្ហាទាំង ៥ខាងលើ។

## ៧.ទិសដៅការងារសម្រាប់ឆ្នាំ២០២៣

ដើម្បីរួមចំណែកធ្វើឲ្យសម្រេចគោលដៅរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ក្នុងការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឆ្នាំ២០២៣នេះ វិទ្យាស្ថាននឹងបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការ ជាមួយអង្គភាពស្រាវជ្រាវជាតិនិងអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងក្រៅស្រុកនានា ដៃគូអភិវឌ្ឍន៍ វិស័យឯកជនពាក់ពន្ធ ក៏ដូចជា កសិករ ដើម្បីអនុវត្តសកម្មភាពស្រាវជ្រាវតាមចង្កោមសកម្មភាពចម្បងចំនួនបីរបស់ខ្លួនគឺ

ចង្កោមសកម្មភាពទី១.៦.១ ការអភិរក្សនិងអភិវឌ្ឍក្លូនកៅស៊ូ និងការសិក្សាលើការអនុវត្តកសិកម្មល្អក្នុងការដាំដុះនិងថែទាំកៅស៊ូដើម្បីបង្កើនផលិតភាពកៅស៊ូ៖ ក្នុងគោលបំណងកសាងនូវទិន្នន័យគោល និងសិក្សាពីកត្តាវិជ្ជមាននិងអវិជ្ជមានដល់ប្រតិបត្តិករដំណាំកៅស៊ូ ដើម្បីបញ្ចៀសនូវហានិយភ័យ ព្រមទាំងការរក្សាបាននូវនិរន្តរភាពផលិតកម្ម និងកំណើនផលចំណូល។ វិទ្យាស្ថាននៅតែបន្តការងារនិងការស្រាវជ្រាវរបស់ខ្លួន ព្រមទាំងខិតខំបន្ថែមទៅលើ (១)ផ្នែកស្រាវជ្រាវអំពីការបង្កាត់ពូជ នឹងពង្រីកទំហំនិងចំនួននៃការថែទាំច្បារពូជ និងច្បារបង្កាត់ពូជកៅស៊ូ ព្រមទាំងបង្កើនចំនួនសំណាក់នៃការប្រមូលសំណាក់ទឹកជ័រក្នុងចម្ការពិសោធន៍ក្លូនដើម្បីវិភាគLD និងបង្កើនចំនួនដងនៃការចុះអង្កេតស្ថានភាពជំងឺកៅស៊ូនៅតាមបណ្តាខេត្តផ្សេងៗទៀត។ (២)ផ្នែកសរីរសាស្ត្រ និងការប្រមូលផលទឹកជ័រនឹងបន្តអភិវឌ្ឍ អភិរក្ស និងគ្រប់គ្រងក្លូនកៅស៊ូបន្ថែម បន្តការពិសោធន៍លើការលាបថ្នាំរំញោចនិងវិភាគរកស្តង់ដាសរីរសាស្ត្រទឹកជ័រ ព្រមទាំងបង្កើនចំនួនចម្ការពិសោធន៍និងសំណាក់ដើម្បីវិភាគសរីរទឹកជ័រ (LD)។ (៣)ការងារដាំដុះនិងការពារ នឹងបន្តការធ្វើពិពិធកម្មដំណាំរួមផ្សំ និងរុក្ខជាតិព្រៃនៅចន្លោះកៅស៊ូ ដំណាំគម្របដី ផលិតកម្មជីវម៉ាស់និងវិធានការគ្រប់គ្រងដំណាំគម្របដី ព្រមទាំងទំនាក់ទំនងរវាងការលូតលាស់ និងទិន្នផល ទៅនឹងអាកាសធាតុ ហើយនិងចង្វាក់ចៀរជ័រ។

ចង្កោមសកម្មភាពទី១.៦.២ ការសិក្សានិងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធិភាព និងការពង្រឹងគុណភាពជ័រកៅស៊ូកម្ពុជាស្របទៅតាមនិយាមអន្តរជាតិ៖ ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវខ្សែច្រវ៉ាក់តម្លៃកៅស៊ូកម្ពុជា និងកិត្យានុភាពផលិតផលយថាប្រភេទកៅស៊ូកម្ពុជាលើទីផ្សារអន្តរជាតិ ក្នុងនោះវិទ្យាស្ថាននៅតែបន្តការងារដូចជា (១)ការធ្វើតេស្តអន្តរមន្ទីរពិសោធន៍ទាំងក្នុងស្រុកនិងក្រៅស្រុក (២)បង្កើនការចុះពិនិត្យបណ្តារោងចក្រកែច្នៃយថាប្រភេទកម្ពុជា(CSR) និងសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជាឲ្យបានយ៉ាងតិចមន្ទីពិសោធន៍ចំនួន០៣ និងរោងចក្រចំនួន០១ (៣)បង្កើនចំនួនសំណាកនៃការធ្វើតេស្តទៅលើកៅស៊ូសន្លឹ (RSS) និងកៅស៊ូដុំ(TSR)។

ចង្កោមសកម្មភាពទី១.៦.៣ ទទួលធ្វើសវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យស្គាល់ជាផ្លូវការនិងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ៖ ក្នុងគោលបំណងកសាងធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ដើម្បីជំរុញការងារពិសោធន៍និងស្រាវជ្រាវ និងការកែលម្អនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ ចង្កោមសកម្មភាពនេះ វិទ្យាស្ថានមានផែនការបណ្តុះបណ្តាលអ្នកជំនាញឲ្យបានយ៉ាងតិច០១នាក់ បង្កើនចំនួននៃការបោះពុម្ពអត្ថបទនិងសៀវភៅស្រាវជ្រាវវិទ្យាសាស្ត្រ ពង្រឹងភាពជាដៃគូស្រាវជ្រាវជាមួយបណ្តាសាកលវិទ្យាល័យ ក្រុមហ៊ុន រោងចក្រកែច្នៃ និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសសមាជិក IRRDB និងអង្គការអន្តរជាតិមួយចំនួន ព្រមទាំងបន្តការយកចិត្តទុកដាក់លើការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ និងកៅស៊ូគ្រួសារ ។

## ១. ព្រឹត្តិការណ៍សំខាន់ៗដែលថ្នាក់ដឹកនាំ និងមន្ត្រីវិទ្យាស្ថានបានចូលរួមក្នុងឆ្នាំ២០២២

លោក **លិម ខាន់ទីវ៉ា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានអមដំណើរ ឯកឧត្តម **ម៉ាន សុត្រី** រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ **ឯកឧត្តម ប៉ុល សុផា** អនុរដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា លោកអគ្គលេខាធិការរងក្រសួងកសិកម្ម និងថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូ ចុះពិនិត្យវឌ្ឍនភាពការងារក្រុមហ៊ុនចម្ការកៅស៊ូក្រុមហ៊ុន ស្វីហ្វ រីសសស៍ (ខេមបូឌា) លីមីធីត ចម្ការកៅស៊ូមេមត់ និងចម្ការកៅស៊ូក្រែកខេមបូឌា។




លោក **លិម ខាន់ទីវ៉ា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងសហការី បានចូលរួមក្នុងពិធីបើកសន្និបាទបូកសរុបការងារប្រចាំឆ្នាំរបស់ខ្លួន ២០២១ និងទិសដៅការងារបន្តសម្រាប់ឆ្នាំ២០២២។





នៅព្រឹកថ្ងៃសៅរ៍ ១១កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២២ លោក **លិម ខាន់ទីវ៉ា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងសហការី បានអញ្ជើញចូលរួមពិធី “រុក្ខទិវា” នៅភូមិសំបូរមាស ឃុំស្នឹង ស្រុកបាណន់ ខេត្តបាត់ដំបង ស្ថិតក្រោមព្រះរាជវត្តមានដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណា** ព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។






លោក **លិម ខាន់ទីវ៉ា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងសហការី បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយអំពីកសិកម្មអភិរក្ស និងប្រពលវប្បកម្មនិរន្តរភាពសម្រាប់ក្រុមហ៊ុនចម្ការកៅស៊ូ និងដីសម្បទានសេដ្ឋកិច្ចនៅកម្ពុជា នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្នុងដំណើរការនៃអង្គសិក្ខាសាលានេះ លោកនាយកវិទ្យាស្ថាន ក៏បានធ្វើបទបង្ហាញផងដែរអំពីឥទ្ធិពលនៃដំណាំគម្របដី និងជីទៅលើដំណាំកៅស៊ូ ដើម្បីចែករំលែកនូវបទពិសោធន៍ក្នុងការជ្រើសរើសប្រភេទដំណាំគម្របដីសមស្របសម្រាប់ដាំដុះនៅក្នុងចម្ការកៅស៊ូ។




## ២. យន្តការតម្រង់ទិសរបស់វិទ្យាស្ថាន

ថ្ងៃចន្ទ ៣កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៤ ខែមេសា ឆ្នាំ២០២២ នៅទីស្នាក់ការវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល វ.ស.ក.ក. លើកទី១០ អាណត្តិឆ្នាំ២០២០-២០២៣ ក្រោមអធិបតីភាព ឯកឧត្តម **ប៉ុល សុផា** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃ វ.ស.ក.ក. ដើម្បីពិនិត្យវឌ្ឍនភាពការងារស្រាវជ្រាវកៅស៊ូក្នុងត្រីមាសទី១ ឆ្នាំ២០២២ និងពិនិត្យរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២១ របស់ វ.ស.ក.ក.។










នាព្រឹកថ្ងៃចន្ទ ៩កើត ខែវិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២ នៅស្ថានីយពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ក្រោមអធិបតីភាពលោក **លិម ខាន់ធីវ៉ា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដើម្បីពិភាក្សាអំពីវឌ្ឍនភាពនៃការអនុវត្តការងារក្នុងខែនីមួយៗ និងលើកទិសដៅសម្រាប់អនុវត្តក្នុងខែបន្ទាប់។





នៅរសៀលថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០២២ ឯកឧត្តម **ម៉ាន សុត្រី** រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អមដំណើរដោយ ឯកឧត្តម **ប៉ុល សុផា** អនុរដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា លោកអគ្គលេខាធិការរងក្រសួងកសិកម្ម និងថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូ បានអញ្ជើញចុះពិនិត្យវឌ្ឍនភាពការងាររបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងជួបសំណេះសំណាលជាមួយមន្ត្រីរាជការនៅស្ថានីយពិសោធន៍វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដែលមានទីតាំងស្ថិតនៅភូមិ៣២ ឃុំជីរោទ៍២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។










នៅរសៀលថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២ លោក **លិម ខាន់ទីវ៉ា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានដឹកនាំកិច្ចប្រជុំស្តីពីការពង្រឹងនិងការគ្រប់គ្រងមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។









ថ្ងៃសុក្រ ១១រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ នៅទីស្នាក់ការ វ.ស.ក.ក. មានក្រុមការងាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដឹកនាំដោយលោក **អ៊ុំ សាវី** អនុប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្សបានជួបពិភាក្សាជាមួយលោក **លិម ខាន់ទីវ៉ា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងសហការី អំពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមព័ត៌មានវិទ្យា។





## ៣. កិច្ចប្រជុំជាមួយដៃគូរជាតិ និងអន្តរជាតិ

នៅរសៀលថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ លោក **លិម ខាន់ទីវ៉ា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានជួបពិភាក្សាការងារជាមួយប្រតិភូ CIRAD អំពីកិច្ចសហប្រតិបត្តិការលើការស្រាវជ្រាវកៅស៊ូ។










នាព្រឹកថ្ងៃសុក្រ ១រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ លោក **ហាក់ ប៊ុនធួន** នាយករងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងជាប្រធានគណៈកម្មការបច្ចេកទេសទី៧ផ្នែកផលិតផលកៅស៊ូ នៃក្រុមប្រឹក្សាស្តង់ដារជាតិ បានដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេសទី៧ ផ្នែកផលិតផលកៅស៊ូពីចម្ងាយតាមប្រព័ន្ធ Zoom Cloud Meeting ដើម្បីពិនិត្យ ពិភាក្សា និងផ្តល់យោបល់លើស្តង់ដារអន្តរជាតិ ISO ដើម្បីដាក់ជូនក្រុមប្រឹក្សាស្តង់ដារជាតិអនុម័តជាស្តង់ដារជាតិ។





លោក **ហាក់ ម៉ុនឆួន** នាយករងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងជាប្រធានគណៈកម្មការបច្ចេកទេសទី៧ ផ្នែកផលិតផលកៅស៊ូ បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាស្តង់ដារជាតិលើកទី២៥ និង២៦តាមប្រព័ន្ធ Video Conference Zoom ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សាត សាមី** រដ្ឋលេខាធិការប្រចាំការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជាប្រធានក្រុមប្រឹក្សាស្តង់ដារ















លោក **លិម ខាន់ទីវ៉ា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានដឹកនាំមន្ត្រីស្រាវជ្រាវនៃ CRRI ចូលរួមប្រជុំតាមប្រព័ន្ធ Video Conference Zoom ជាមួយថ្នាក់ដឹកនាំ និងអ្នកវិទ្យាសាស្ត្រវិទ្យាស្ថានស្រាវជ្រាវកៅស៊ូនៃបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន RRI-CATAS ហើយកិច្ចប្រជុំនេះក៏មានការអញ្ជើញចូលរួម និងថ្លែងបើកកិច្ចប្រជុំដោយលោកបណ្ឌិត Wang Xiangshe លេខាធិការទី១នៃស្ថានទូតចិនប្រចាំប្រទេសកម្ពុជាផងដែរ។



















## ៤. ការថែទាំច្បារពូជ និងច្បារបង្កាត់ពូជ



ច្បារបង្កាត់ពូជ



ច្បារពូជកៅស៊ូ



សកម្មភាពរៀបចំទីតាំងស្រង់ជំងឺ Oidium



ការថែទាំកូនកៅស៊ូ TCPs



សកម្មភាពវាស់ទំហំដើមកៅស៊ូពិសោធន៍



សកម្មភាពប្រមូលទិន្នន័យជីវ

## ៨. ការថែទាំថ្នាលបណ្តុះកូនកៅស៊ូ



សកម្មភាពដាក់គ្រាប់កៅស៊ូក្នុងថង់នៅថ្នាលបណ្តុះកូន



ការជួសកូនកៅស៊ូស៊ីងលីង (Seedling) ក្នុង



ការបំបៅកូនកៅស៊ូ ឆ្នាំ២០២១ សម្រាប់ដាំដុះឆ្នាំ ២០២២



សកម្មភាពកាត់ដើមទំរ



ការដាក់ជីបំប៉នកូនកៅស៊ូស៊ីងលីង (Seedling)



ការបាញ់Dithan M45 ការពារនិងព្យាបាលជំងឺ

## ៦. ការដាំដុះ និងការពារ

















## ៧. ការងារក្នុងចម្ការពិសោធន៍

















## ៨. ការពិសោធន៍នៅមន្ទីរពិសោធន៍ជាតិយថាប្រភេទ



សកម្មភាពនៃការធ្វើតេស្ត$P_0$ និងPRI



សកម្មភាពធ្វើការធ្វើតេស្តវីស្កូស៊ីធីមូនី



សកម្មភាពនៃការធ្វើតេស្តរកបរិមាណផេះ



សកម្មភាពនៃការធ្វើតេស្តរកបរិមាណអាសូត



សកម្មភាពនៃការធ្វើតេស្តរកសារធាតុហើរ



សកម្មភាពនៃការធ្វើតេស្តរកអសុទ្ធភាព





ការកិនគំរូសំណាកឱ្យស្មើសាច់ដើម្បីបែងចែក

ការធ្វើតេស្តរកសន្ទស្សន៍ពណ៌





ការចុះពិនិត្យតាមដាន និងពង្រឹងគុណភាពក្នុងការកែច្នៃកៅស៊ូរបស់រោងចក្រយថាប្រភេទ (CSR) និងមន្ទីរពិសោធន៍មូលដ្ឋាននៃក្រុមហ៊ុន សុកហ្វីន ខូ., អិលធីឌី









ការចុះពិនិត្យ និងវាយតម្លៃមន្ទីរពិសោធន៍ និងការធ្វើបង្ហាញពីការធ្វើតេស្តមួយចំនួនបុគ្គលិកនៃក្រុមហ៊ុន ក្រុងបុក រតនគិរីអភិវឌ្ឍន៍កៅស៊ូ ខូ ,.អិលធីឌី









សកម្មភាពចុះពិនិត្យ និងវាយតម្លៃរោងចក្រកែច្នៃកៅស៊ូ (CSR) និងមន្ទីរពិសោធន៍មូលដ្ឋាន នៃក្រុមហ៊ុនស៊ីធីរ៉ាប់បើ ខូ., អិលធីឌី









ការចុះពិនិត្យវាយតម្លៃរោងចក្រកែច្នៃកៅស៊ូ TSR របស់ក្រុមហ៊ុនចំការកៅស៊ូមេមត់ ខូ ,.អិលធីឌី





កិច្ចពិភាក្សាអំពីការចុះបញ្ជិកាពោងចក្រកែច្នៃកៅស៊ូ និងការបំពេញឯកសារចុះបញ្ជិកា





ពិនិត្យទីតាំងធ្វើDRC និងអាងទឹកជ័រលាយអាស៊ីត

ការពិភាក្សាអំពីសីតុណ្ហភាពផលិតផលសម្រេចមុនវេចខ្ចប់

ការចុះពិនិត្យ និងវាយតម្លៃរោងចក្រកែច្នៃកៅស៊ូ (CSR) និងមន្ទីរពិសោធន៍មូលដ្ឋាននៃក្រុមហ៊ុន ស៊ីហ្វ រីសសស៍ (ខេមបូឌា) លីមីធីត





## ៩. ការពិសោធន៍សរីរសាស្ត្រទឹកជ័រ



សកម្មភាពវិភាគសរីរសាស្ត្រទឹកជ័រ
(Latex diagnosis-LD, Sucrose, Pi, R-SH)



ការវិភាគរកស្តង់ដារសរីរសាស្ត្រទឹកជ័រ
ដើម្បីផ្ទៀងផ្ទាត់សារធាតុគីមី





សកម្មភាពយកសំណាកទឹកជ័រដើម្បីវិភាគសរីរទឹកជ័រ

## ១០. ការផ្សព្វផ្សាយ និងបណ្តុះបណ្តាល

ការណែនាំបច្ចេកទេសចៀរជ័រកៅស៊ូដល់កសិករកៅស៊ូគ្រួសារក្រោមកិច្ចសហការជាមួយអង្គការ FNN





ការណែនាំបច្ចេកទេសចៀរជ័រកៅស៊ូដល់កសិករកៅស៊ូគ្រួសារក្រោមកិច្ចសហការជាមួយអង្គការ WWF





ក្រុមកសិករបានចុះស្វែងយល់ពីពីច្បារពូជកៅស៊ូរបស់កសិករកៅស៊ូគ្រួសារ និងសមិទ្ធផលស្រាវជ្រាវរបស់វិទ្យាស្ថានស្រាវ
កៅស៊ូកម្ពុជា





មន្ត្រីជំនាញចំនួនពីររូបនៃវិទ្យាស្ថានទៅបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូ ដល់កសិករផលិតកៅស៊ូខ្នាតតូចចំនួន០៤ក្រុម នៅសហគមន៍កសិកម្មស្ថិតក្នុងខេត្តត្បូងឃ្មុំ សហគមន៍កសិកម្មសាមគ្គីកក់ សហគមន៍កសិកម្មពពេលមានជ័យ សហគមន៍កសិកម្មបៃតងគោកស្រុក និងសហគមន៍កសិកម្មល្បៀងមានជ័យ។ ការបណ្តុះបណ្តាលនេះបានប្រព្រឹត្តទៅពីថ្ងៃទី១៣ ដល់ ១៦ ខែកក្កដា ឆ្នាំ២០២២ ដែលត្រូវបានចែកចេញជាពីរផ្នែកសំខាន់ៗ គឺផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែងនៅទីតាំងចម្ការផ្ទាល់។










មន្ត្រីជំនាញចំនួនពីររូប ទៅបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដល់កសិករផលិតកៅស៊ូខ្នាតតូច ចំនួន ០៥ក្រុម នៅសហគមន៍កសិកម្មស្ថិតក្នុងខេត្តត្បូងឃ្មុំ។ ការបណ្តុះបណ្តាលនេះបានប្រព្រឹត្តទៅពីថ្ងៃទី១៧ ដល់ ២១ ខែតុលា ឆ្នាំ២០២២ ដែលត្រូវបានចែកចេញជាពីរផ្នែកសំខាន់ៗ គឺផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែងនៅទីតាំង

















ថ្ងៃទី២៧-២៩ ខែតុលា ឆ្នាំ២០២២ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានសហការជាមួយវេទិកាសកល ស្តីពីនិរន្តរភាពកៅស៊ូធម្មជាតិ (GPSNR) អង្គការស្រាវជ្រាវកសិកម្មនិងសហប្រតិបត្តិការអន្តរជាតិនៃប្រទេសបារាំង (CIRAD) និងអង្គការមូលនិធិសកលសម្រាប់ធម្មជាតិ(WWF) បានរៀបចំសិក្ខាសាលាស្តីពីកសិរុក្ខកម្មកៅស៊ូ នៅស្ថានីយពិសោធន៍នៃ CRRI ស្ថិតក្នុងឃុំជីរោទិ៍២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។



















ការបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូនៅដំណាក់កាលទី១ដែលបានបណ្តុះបណ្តាលកសិករផលិតកៅស៊ូខ្នាតតូចចំនួន ០៤សហគមន៍រួចមកហើយ លោក **លិម ខាន់ទីវ៉ា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា **(វ.ស.ក.ក.)** បានបន្តចាត់មន្ត្រីជំនាញចំនួនពីររូប ទៅបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដល់កសិករផលិតកៅស៊ូខ្នាតតូចចំនួន០២ សហគមន៍បន្ថែមទៀតនៅដំណាក់កាលទី២តាមសំណើរបស់សមាគមបណ្តាញកសិករ និងធម្មជាតិ (ប.ក.ធ)។ ការបណ្តុះបណ្តាលនេះ បានប្រព្រឹត្តទៅពីថ្ងៃទី២៨ ដល់ ២៩ ខែកក្កដា ឆ្នាំ២០២២ នៅសហគមន៍កសិកម្មទ្រទ្រង់កសិករ ឃុំអូរម្លូ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម និងសហគមន៍កសិកម្មកសិករតំបែរ ឃុំទឹកជ្រៅ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ ហើយការបណ្តុះបណ្តាលនេះ ត្រូវបានចែកចេញជាពីរផ្នែកសំខាន់ៗ គឺផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែងនៅទីតាំងចម្ការផ្ទាល់។








ថ្នាក់ដឹកនាំ និងមន្ត្រីនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានធ្វើការបណ្តុះបណ្តាលលើប្រធានបទចំនួន០៣ (១) ការរៀបចំច្បារពូជកៅស៊ូតាមបទដ្ឋានបច្ចេកទេស (២)អត្តសញ្ញាណកម្មក្លូនកៅស៊ូ និង(៣)ការជ្រើសរើសពូជដែលសមស្របទៅតាមទីតាំងភូមិសាស្ត្រដាំដុះ ដល់កសិករមួយក្រុមមានគ្នាសរុបចំនួន១៥នាក់ ដែលបានអញ្ជើញមកពីស្រុកចំនួន០៣ ស្រុកពញាក្រែក តំបែរ និងមេមត់ ខេត្តត្បូងឃ្មុំ។

















## ១១. ការចុះទស្សនកិច្ចនៅស្ថានីយអនុវត្តនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ការចុះទស្សនកិច្ចរបស់និស្សិតជប៉ុនមកពី ERECON ចុះកម្មសិក្សាស្វែងពីដំណើរការធ្វើតេស្តគុណភាពកៅស៊ូយថាប្រភេទ





ការចុះទស្សនកិច្ចរបស់និស្សិតផ្នែកគីមីឧស្សាហកម្មឆ្នាំទី៤នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា បានមកទស្សនកិច្ចសិក្សាស្រាវជ្រាវលើការវិភាគគុណភាពកៅស៊ូយថាប្រភេទ



សកម្មភាពនៃការបង្ហាញឧបករណ៍បំណិតអាសូត



សកម្មភាពនៃការបង្ហាញឧបករណ៍ធីត្រេអាសូត



សកម្មភាពនៃការបង្ហាញឧបករណ៍ស្គវីស្គូស៊ីធីមូនី



សកម្មភាពនៃការបង្ហាញពីស្តង់ដាររបស់$P_0$ និងPRI

តបតាមសំណើរបស់បណ្ឌិត **ម៉ូ គឹមថូ** នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា លោក **លិម ខាន់ធីវ៉ា** នាយក វ.ស.ក.ក. បានអនុញ្ញាតឲ្យសាស្ត្រាចារ្យ និងនិស្សិតនៃមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍ នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា មកធ្វើទស្សនកិច្ចសិក្សាស្រាវជ្រាវស្វែងយល់អំពីដំណើរការប្រមូលទឹកជ័រ វិធីសាស្ត្រកែច្នៃកៅស៊ូសន្លឹក (RSS) និងការវិភាគគុណភាពកៅស៊ូធម្មជាតិសម្រាប់ការនាំចេញ ក្នុងគោលបំណងបង្កើននូវចំណេះដឹង ដែលបានសិក្សាទ្រឹស្តីកន្លងមក។ ការធ្វើទស្សនកិច្ចនេះ ប្រព្រឹត្តទៅចំនួនពីរថ្ងៃ គឺនៅថ្ងៃទី២២-២៣ ខែកញ្ញា ឆ្នាំ២០២២ នៅស្ថានីយពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។













ទស្សនកិច្ចរបស់គណៈប្រតិភូ CIRAD, IRD និង GDA នៅស្ថានីយពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
នៅរសៀលថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២។










# ១២. ឯកសារបោះពុម្ពផ្សព្វផ្សាយ



### ៤. ការការពារជំងឺ

ជំងឺភ្នែកចាប មិនសូវគ្រោះថ្នាក់ទេនៅក្នុងថ្នាលបណ្តុះកូនដែលដីមានជីជាតិគ្រប់គ្រាន់។ ការថែទាំត្រូវបានយកចិត្តទុកដាក់នៅពេលបង្កើតថ្នាលកូន ហើយត្រូវចៀសវាងដីខ្សាច់ខ្វាំងពេក ឬដីគ្រួសថ្មដែលអាចធ្វើឱ្យកូនកៅស៊ូងាយរងគ្រោះដោយសារគ្រោះរាំងស្ងួត។



### ៥. ការព្យាបាល

ដើម្បីព្យាបាលជំងឺប្រកបដោយជោគជ័យ ត្រូវបាញ់ថ្នាំសម្លាប់ផ្សិតក្នុងចន្លោះមួយសប្តាហ៍ម្តងនូវប្រភេទថ្នាំដូចជា៖

- ម៉ង់កូសែប (Mancozeb) ក្នុងកម្រិត ០,២%
- ប្រូពីនែប (Propineb) ក្នុងកម្រិត ០,២%
- កាបិនដាស៊ីម (Carbendazim)ក្នុងកម្រិត០,០២%
- ឌីទីអូកាបានមាត(Dithiocarbamate)ក្នុងកម្រិត ២%
- បាវីសស្ទីន (Bavistin) ក្នុងកម្រិត ០,៤មីលីលីត្រ /១លីត្រទឹក។



**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**
អាសយដ្ឋាន: អគារលេខ ៥៩E ផ្លូវបេតុង ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ឬ ប្រអប់សំបុត្រលេខ ១៣៣៧ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥) ៧៨ ៦៨២ ២២២
សារអេឡិចត្រូនិច : crri@camnet.com.kh
វិបសាយ : www.crri.com.kh

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ប័ណ្ណបច្ចេកទេស ២០២២/០២

## ជំងឺភ្នែកចាប
## Bird's eye spot leaf disease



ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យផ្សាំផុះនិងការពារ

### ១. លក្ខណៈទូទៅ

ជាទូទៅជំងឺភ្នែកចាប (Bird's eye spot disease) តែងតែកើតមានឡើងនៅក្នុងថ្នាលបណ្តុះកូន អំឡុងពេលនៃអាកាសធាតុស្ងួត។ ជំងឺប្រភេទនេះមានកើតច្រើននៅលើកៅស៊ូ ហើយវាមិនបណ្តាលឱ្យដើមកៅស៊ូងាប់ទេ ប៉ុន្តែវាអាចធ្វើឱ្យដើមកៅស៊ូទាំងមូលចុះខ្សោយនិងជ្រុះស្លឹក។ កូនកៅស៊ូដែលកើតជំងឺនេះដុះលូតលាស់យឺតយ៉ាវក្រុបានយកទៅដាំឬក្របានបំប៉ៅ។ ភាគច្រើនវាកើតនៅលើដើមកៅស៊ូដែលដាំនៅលើដីខ្វះជីជាតិ ។

### ២. រោគសញ្ញាជំងឺ

ជំងឺភ្នែកចាបមានស្នាមអុជរាងមូលទំហំ ១-៣ម.ម. មានចំណុចភ្លឺថ្លានៅចំកណ្តាល និងព័ទ្ធជុំវិញដោយរឹមតូចពណ៌ត្នោត។ ស្លាកស្នាមអុជនេះបណ្តាលមកពីផ្សិតវាតត្បាតនៅពេលស្លឹកធំពេញរូបរាង ប៉ុន្តែស្លឹកនៅខ្ចីនៅឡើយ។ នៅលើស្លឹកខ្ចី ការវាតត្បាតនៃជំងឺធ្វើឱ្យមានស្លាកស្នាម អុចពណ៌ខ្មៅនៅរាយប៉ាយនិងរាលដាលនៅពេញផ្ទៃស្លឹកហើយធ្វើឱ្យស្លឹកជ្រីវជ្រួញ។ នៅលើស្លឹកចាស់ មានស្នាមដំបៅ (lesion) ជាចំណុចតូចៗមានពណ៌ត្នោត។ ជំងឺនេះត្រូវបានឃើញកើតមាននៅលើកូនកៅស៊ូស៊ីដលីង ច្រើនជាងកូនកៅស៊ូបំប៉ៅ។ នៅលើដើមកៅស៊ូចាស់ ជំងឺភ្នែកចាប មិនឃើញកើតមានទេ ហើយក៏មិនសំខាន់នោះដែរ។



### ៣. ភ្នាក់ងារបង្កជំងឺ

ជំងឺភ្នែកចាប បង្កឡើងដោយផ្សិត *Drechslera heveae* ឬ *Helminthosporium heveae* ដែលបង្កើតនូវស្ប៉ (spores) វែងធំពណ៌ត្នោតក្រម៉ៅដែលអាចមើលឃើញដោយប្រដាប់ឆ្លុះកាន់ដៃ (hand lens)។ នៅពេលបញ្ចេញស្ប៉ គេឃើញស្ប៉ពណ៌ត្នោតស្រអាប់ជាច្រើនស្ថិតនៅចំកណ្តាល នៃស្នាមអុជនៅផ្នែកខាងក្រោមផ្ទៃស្លឹក។ ស្ប៉ទាំងនោះនឹងបែកសាយភាយចេញដោយខ្យល់នាំទៅរយៈចម្ងាយឆ្ងាយ។

ទឹកភ្លៀង សន្សើម និង ទំនាក់ទំនងពីដើមមួយទៅដើមមួយ គឺជាមូលហេតុធ្វើឱ្យស្ប៉ដាច់ចេញពីស្នាមដំបៅទៅកន្លែងផ្សេងទៀត។ កាលណាបើជំងឺនេះកើតឡើងនៅក្នុងថ្នាលបណ្តុះកូន វានឹងរាលដាលយ៉ាងឆាប់រហ័ស ហើយស្លឹកកៅស៊ូកម្រគេចផុតពីជំងឺនេះណាស់។ ក្រៅពីដើមកៅស៊ូ គេពុំឃើញមានរុក្ខជាតិផ្សេងទៀតជារុក្ខជាតិជម្រកនៃជំងឺផ្សិតនេះទេ។



### ៤. បញ្ហាប្រឈម

- ជំងឺស្លឹកកៅស៊ូ Pestalotiopsis ជាជំងឺស្លឹកដ៏គ្រោះថ្នាក់និងរាលដាលលឿនបំផុតសម្រាប់ចម្ការកៅស៊ូ
- ជំងឺនេះកើតមានតែលើស្លឹកចាស់នៅចម្ការកៅស៊ូពេញវ័យអាយុចាប់ពី៨ឆ្នាំឡើង (កៅស៊ូប្រមូលផលទឹកជ័រ)
- ជំងឺស្លឹកកៅស៊ូ Pestalotiopsis បណ្តាលឱ្យកៅស៊ូជ្រុះស្លឹកពី៧០-៩០% និងបាត់បង់ទិន្នផលពី ២៥-៥០% ។











**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

អាសយដ្ឋាន: អគារលេខ ៥៩E ផ្លូវបេតុង ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ឬ ប្រអប់សំបុត្រលេខ ១៣៣៧ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

| | |
|---|---|
| ទូរស័ព្ទ | : (៨៥៥) ៧៨ ៦៨២ ២២២ |
| សារអេឡិចត្រូនិច | : crri@camnet.com.kh |
| វែបសាយ | : www.crri.com.kh |

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ប័ណ្ណបច្ចេកទេស ២០២២/០១

# ជំងឺស្លឹកកៅស៊ូ Pestalotiopsis





ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យដាំដុះនិងការពារ

### ១. ប្រវត្តិនៃជំងឺ

នៅឆ្នាំ២០១៦ ជំងឺ Pestalotiopsis កើតមាននៅភាគខាងជើងកោះស៊ូម៉ាត្រា បន្ទាប់មកនៅឆ្នាំ២០១៧ បានរាតត្បាតដល់ភាគខាងត្បូងកោះស៊ូម៉ាត្រានៃប្រទេសឥណ្ឌូនេស៊ី ហើយបន្តកើតមានរហូតដល់បច្ចុប្បន្ន។ ជំងឺនេះបានរាលដាលដល់ប្រទេសម៉ាឡេស៊ី នៅឆ្នាំ២០១៧ និងប្រទេសថៃនៅឆ្នាំ២០១៩។ ឆ្នាំ២០២០ ជំងឺ Pestalotiopsis បានកើតមាននៅប្រទេសផលិតកៅស៊ូធម្មជាតិចំនួន៥ គឺប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី ឥណ្ឌា ស្រីលង្កា និងថៃ ហើយត្រូវបានប្រកាសអាសន្ននៅក្នុងបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ។ ដោយឡែក នៅប្រទេសកម្ពុជាយើង ជំងឺនេះត្រូវបានឃើញកើតមាននៅស្រុកបុទុមសាគរខេត្តកោះកុងក្នុងឆ្នាំ២០២១។

### ២. រោគសញ្ញាជំងឺ

ជំងឺស្លឹកកៅស៊ូ Pestalotiopsis បង្កឡើងដោយផ្សិត *Pestalotiopsis* species។ ជំងឺកើតលើស្លឹកកៅស៊ូចាស់(កៅស៊ូចាប់ពីអាយុ៨ឆ្នាំឡើង)។



រោគសញ្ញាកើតលើស្លឹកគឺមានស្នាមជាំជារង្វង់នៅផ្នែកខាងក្រោម និងស្នាមអុចតូចៗពណ៌លឿងនៅផ្នែកខាងលើ បន្ទាប់មកស្នាមអុចនេះប្រែទៅជាពណ៌ខ្មៅ ក្រោយមកនៅលើស្លឹកមានរាងជារង្វង់ពណ៌ត្នោតហើយស្ងួតៗ ស្លឹកចាប់ផ្តើមប្រែពណ៌ទៅជាលឿង ហើយចាប់ផ្តើមជ្រុះទាំងស្លឹកពណ៌បៃតងនិងស្លឹកពណ៌លឿង។









### ៣. ការព្យាបាល

កៅស៊ូដែលកើតទូវជំងឺនេះ ត្រូវចាំបាច់ធ្វើការព្យាបាលជាបន្ទាន់។ ការព្យាបាល ត្រូវបាញ់ថ្នាំលើកន្សោមស្លឹក និងស្លឹកជ្រុះលើដីចំនួន៣-៦ដងដោយប្រើថ្នាំគីមីមានដូចជា៖

- ក្លរ៉ូតាឡូនីល (chlorothalonil)
- ប្រូពីនេប ឬប្រូពីកូណាសូល (propineb or propiconazole)
- បេណូមីល (benomyl) កម្រិត ០,០២%
- ហិចសាកូណាសូល (hexaconazole) កម្រិត ០,៥ លីត្រក្នុងមួយហិកតា
- ម៉ង់កូសែប (mancozeb) កម្រិត ០,២%









# ឯកសារបោះពុម្ពផ្សព្វផ្សាយ

## ២. កំហាប់នៃថ្នាំរំញោច

ចំពោះកំហាប់ 2.5% នៃល្បាយថ្នាំរំញោច ដែលត្រូវលាប បរិមាណកំណត់ជាមធ្យម គឺ១ក្រាម សម្រាប់លាបមួយដើម សម្រាប់ការចៀរពាក់កណ្ដាលគូទខ្យង (S/2)។ ករណីចៀរឡើងលើ (S/4U) ឬចៀរសម្រាប់ដើមចុងក្រោយ ល្បាយថ្នាំរំញោចអាចមានកំហាប់អេតេហ្វុន 5%។

ដើម្បីចៀសវាងការរំញោចលើសកម្រិត បរិមាណដែលបានកំណត់នៃរូបធាតុសកម្ម (ជាមីលីក្រាមសម្រាប់មួយដើមក្នុងមួយឆ្នាំ) មិនត្រូវឱ្យលើសជាដាច់ខាត។ បរិមាណនេះ គឺអាស្រ័យទៅតាមក្រុមក្លូនកៅស៊ូនិងប្រព័ន្ធចៀរ។

## ៣. ចំនួនជុំ (Rounds) នៃការរំញោច

ការរំញោចមួយលើក ទៅមួយលើកទៀត ត្រូវមានគម្លាតពេលគ្រប់គ្រាន់ ដើម្បីទុកឱ្យដើមកៅស៊ូមានពេលអាចបង្កើតទឹកជ័រឡើងវិញ ស្របទៅតាមបរិមាណថ្នាំនិងប្រព័ន្ធចៀរដែលគេប្រើ។ ការរំញោចនេះត្រូវធ្វើច្រើនដង ឬ តិចក្នុងមួយឆ្នាំ គឺអាស្រ័យទៅតាមក្រុមក្លូន (Clonal typology)។

## ៤. ពេលត្រូវរំញោច

- ការរំញោចត្រូវប្រព្រឹត្តទៅឱ្យបានមុនការចៀរជ័រ ពី២៤-៤៨ម៉ោង អាស្រ័យតាមចន្លោះចៀរ។

ការរំញោចលើសកំណត់ អាចធ្វើឱ្យមានវិបត្តិដល់សរីរៈនៃដើមកៅស៊ូនិងបណ្ដាលឱ្យដើមកៅស៊ូអន់ខ្សោយ ដែលអាចនាំឱ្យសម្បកស្ងួត ទឹកជ័រលែងហូរ និងនាំឱ្យមានបាតុភូតដែលគេហៅថា**ស្ងួតមុខចៀរ** (Tapping Panel Dryness)។

## ការប្រុងប្រយ័ត្ន

ក្នុងការរំញោច ត្រូវប្រុងប្រយ័ត្នដូចតទៅ៖

- ត្រូវចៀសវាងធ្វើការរំញោចក្នុងពេលដែលដើមកៅស៊ូកំពុងជ្រុះនិងដុះស្លឹកឡើងវិញ
- មិនត្រូវលាបថ្នាំរំញោចនៅពេលភ្លៀង
- ត្រូវរក្សាទុក ឬដឹកជញ្ជូនល្បាយសារធាតុរំញោចនៅក្នុងធុងមិនមែនលោហៈ។

សូមទាក់ទងជាមួយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បើលោក-អ្នកចង់ដឹងលម្អិតអំពីការរំញោច។

**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

អាស័យដ្ឋានលេខ 59E ផ្លូវលេខ ... សង្កាត់... ខណ្ឌ... រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ឬ ប្រអប់សំបុត្រលេខ 1337 រាជធានីភ្នំពេញ

ទូរស័ព្ទ/ទូរសារ : (855) 78 682222

សារអេឡិចត្រូនិច : crri@camnet.com.kh

វិបសាយ : www.crri.com.kh

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

បណ្ណបត្រកវេស ២០២៤/១០

# ការរំញោចទឹកជ័រដោយប្រើអេតេហ្វុន



ការផ្សព្វផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យសាកលវិទ្យានិងអាជីវកម្ម

1/2

## និយមន័យការរំញោច (Stimulation)

ការរំញោច គឺជាវិធីប្រើផលិតផលគីមីដើម្បីទាញយកទឹកជ័រឱ្យបានច្រើន ដោយវាមិនធ្វើឱ្យមុខសរសៃជ័រដាច់ស្ទះ និងធ្វើឱ្យទឹកជ័រហូរចេញបានយូរជាលទ្ធផល ការរំញោចធ្វើឱ្យកសិករទទួលបានជ័រកៅស៊ូច្រើន ដោយពុំចាំបាច់បង្កើនប្រវែងមុខចៀរឬចន្លោះចៀរណា។

## អត្ថប្រយោជន៍នៃការរំញោច

ការរំញោចនឹងជួយ៖

- បង្កើនបរិមាណទឹកជ័រនៃមុខចៀរជ័រ ហើយស្របគ្នានោះប្រាក់កម្រៃរបស់អ្នកចៀរក៏កើនឡើងដែរ។
- ការចំណាយសម្បកអស់តិច។ ព្រោះហេតុនេះបានជាដើមកៅស៊ូមានរយៈពេលចៀរយកជ័របានយូរឆ្នាំ។
- បន្ថយចន្លោះចៀរ ប៉ុន្តែអាចយកផលបានដូចចន្លោះញឹក ឬ បានច្រើនជាង។ ដូចនេះ គេប្រើកម្លាំងពលកម្មតិចដែលធ្វើឱ្យសោហ៊ុយចំណាយក្នុងការប្រមូលផលថយចុះ ឯទិន្នផលនៅដដែល។
- ពន្យារការចៀរសម្បកដែលដុះថ្មីឡើងវិញ។ ដូច្នេះសម្បកដែលដុះថ្មីនេះ មានលក្ខណៈពេញលេញហើយមានសភាពល្អប្រសើរ។

## អំពីល្បាយថ្នាំរំញោច

សារធាតុថ្នាំរំញោចដែលគេនិយមប្រើច្រើនជាងគេគឺ "**អេតេហ្វុន** - Ethephon" ឬ ឈ្មោះគីមីហៅថា **អាស៊ីត ២ ក្លរអេទីល - ផូស្វ៊ូរិក** (2 chloroethyl-phosphoric acid)។ គេអាចស្គាល់ផងដែរថ្នាំរំញោចនេះ ក្រោមឈ្មោះ "**អេត្រែល** - Ethrel"។

អេតេហ្វុនត្រូវបានលាបក្រោមរូបភាពជាល្បាយជាមួយទឹក ឬ ប្រេង (ដូងប្រេង)។ លើទីផ្សារអាចមានល្បាយដែលមានកំហាប់ផ្សេងៗ (2.5%, 5%,...)។

## ការរំញោច

ការរំញោចមានច្រើនវិធី ប៉ុន្តែវិធីដែលគេច្រើនអនុវត្តគឺវិធីលាបថ្នាំរំញោចដោយប្រើជក់លាប។

### ១. វិធីលាបថ្នាំរំញោច

នៅក្នុងចំណោមវិធីលាបផ្សេងៗ វិធីលាបនៅលើសម្បកដែលដុះឡើងវិញ (panel application) ត្រូវបានគេនិយមប្រើជាងគេ។

ក្នុងករណីនេះ ថ្នាំរំញោចត្រូវបានលាបផ្ទាល់លើមុខចៀរ (tapping cut) ទៅតាមប្រវែងមុខចៀរ (ផ្ទៃលាបមានទទឹងប្រមាណ ១សង់ទីម៉ែត្រ) នៅលើសម្បកដែលដុះឡើងវិញ។

វិធីនេះមានភាពងាយស្រួល ហើយចំណាយតិច។ ហេតុនេះហើយ វិធីនេះត្រូវបានគេអនុវត្តច្រើនជាងគេ។




Downward tapping
**មុខចៀរចុះក្រោម**




Upward tapping
**មុខចៀរឡើងលើ**

**វិធីលាបលើសម្បកដែលដុះឡើងវិញ**
Panel application (Eric Gohet, 2012)



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ផែនការយុទ្ធសាស្ត្រ
ស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាកៅស៊ូ
នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ឆ្នាំ២០២០-២០៣០

រាជធានីភ្នំពេញ ឆ្នាំ២០២២

